**ការផ្គត់ផ្គង់សន្លឹកឆ្នោត និងសម្ភារឧបករណ៍ចាំបាច់សម្រាប់ការបោះឆ្នោត**

**ប្រការ ៩.២.-**

គ.ជ.ប ត្រូវផ្គត់ផ្គង់សន្លឹកឆ្នោត និងឧបករណ៍សម្រាប់បម្រើឱ្យការបោះឆ្នោតតាមការិយាល័យបោះឆ្នោតនៃឃុំ សង្កាត់ ឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលា។

៩.២.១ គ.ជ.ប ធានាបោះពុម្ពសន្លឹកឆ្នោតគ្រប់ចំនួនសម្រាប់ឃុំ សង្កាត់នីមួយៗ នៅលើក្រដាសពណ៌ស ។

៩.២.២ សន្លឹកឆ្នោតនីមួយៗ ត្រូវមានគល់បញ្ជីសន្លឹកឆ្នោត ។ លេខរៀងតាមលំដាប់តគ្នានៃសន្លឹកឆ្នោត ត្រូវបោះនៅលើគល់បញ្ជីសន្លឹកឆ្នោត ។

៩.២.៣ សន្លឹកឆ្នោតនីមួយៗ ត្រូវមានសញ្ញាសម្គាល់គណបក្សនយោបាយ និងឈ្មោះគណបក្សនយោបាយជាអក្សរពេញ និងអក្សរកាត់ ។ សញ្ញាសម្គាល់គណបក្សនយោបាយ និងឈ្មោះគណបក្សនយោបាយជាអក្សរពេញ និងអក្សរកាត់ដែលត្រូវដាក់នៅលើសន្លឹកឆ្នោត ត្រូវដាក់តាមលំដាប់លំដោយ ផ្អែកតាមលទ្ធផលនៃការចាប់ឆ្នោត ដូចមានចែងក្នុងមាត្រា ៦៤ ច.ប.ឃ.ស ។

៩.២.៤ ឃុំ សង្កាត់នីមួយៗ ត្រូវមានសន្លឹកឆ្នោតដោយឡែករបស់ខ្លួន ដែល គ.ជ.ប ផ្តល់ជូន ។

៩.២.៥ គ.ជ.ប ត្រូវធានាផ្តល់ហិបឆ្នោតឱ្យបានគ្រប់ចំនួន សម្រាប់ឃុំ សង្កាត់នីមួយៗ ។ គ្រប់ហិបឆ្នោតទាំងអស់ត្រូវ ៖

- មានគម្របជាប់មកជាមួយ ដែលអាចចាក់បិទបានដោយប្រើប្រាស់សោឃ្លុំមានលេខ
- ធានានូវសុវត្ថិភាព ដែលមិនអាចហូតយកសន្លឹកឆ្នោតចេញពីក្នុងហិបបាន ប្រសិនបើមិនបើកគម្រប
- មានសោ ឬឧបករណ៍ផ្សេងទៀតសម្រាប់កិបពេលបិទហិបឆ្នោត
- មានស្លាកលេខ ឬសញ្ញាសម្គាល់នៅផ្នែកខាងក្រៅយ៉ាងច្បាស់ដែលមិនអាចដូរ ឬលុបបានដោយងាយ ហើយស្លាកលេខ ឬសញ្ញាសម្គាល់នេះ ត្រូវមានតែមួយគត់សម្រាប់ហិបឆ្នោតនោះ និងសម្គាល់បានថា ហិបឆ្នោតនោះទាក់ទងទៅនឹងឃុំ សង្កាត់ និងការិយាល័យបោះឆ្នោតណាមួយ ។

៩.២.៦ គ.ជ.ប ត្រូវធានាឱ្យមានត្រាសម្ងាត់ជាផ្លូវការគ្រប់ចំនួន និងខុសៗគ្នា សម្រាប់ការិយាល័យបោះឆ្នោតនៃឃុំ សង្កាត់នីមួយៗ ។

គ.ជ.ប ត្រូវតាក់តែងបទបញ្ជា និងនីតិវិធីសម្រាប់ការប្រគល់ទទួល និងការប្រគល់ត្រឡប់មកវិញ និងធានាឱ្យភាពសម្ងាត់នៃត្រានេះ ។

៩.២.៧ គ.ជ.ប ត្រូវធានាឱ្យការិយាល័យបោះឆ្នោតនីមួយៗ មានសម្ភារ ឧបករណ៍ ដូចខាងក្រោម ៖

១- បញ្ជីបោះឆ្នោត ។

២- សន្លឹកឆ្នោតមិនទាន់ប្រើប្រាស់ ។

៣- ហិបឆ្នោត ដែលអាចចាក់ជាមួយសោឃ្លុំមានលេខ ។

៤- បន្ទប់សម្ងាត់ ។

៥- ត្រាការិយាល័យ ។

៦- ត្រាសម្ងាត់សម្រាប់បោះលើសន្លឹកឆ្នោត ។

៧- ទឹកខ្មៅលុបមិនជ្រះ សម្រាប់ជ្រលក់ម្រាមដៃសម្គាល់ថាបានបោះឆ្នោតហើយ ។

៨- សោ និងប្រដាប់ឃ្លុំ ។

៩- ទម្រង់បែបបទសម្រាប់បំពេញកំណត់ហេតុ និងសម្រង់លទ្ធផល ។

១០- ប៊ិកសរសេរដែលមានគុណភាពល្អ ។

១១- ស្រោមសំបុត្រដែលបោះពុម្ពលើខ្នងរួចហើយ ។

១២- ថង់ប្លាស្ទិក ។

១៣- សម្ភារ និងបរិក្ខារចាំបាច់ផ្សេងៗ ទៀត ។

**ភារទទួលខុសត្រូវ និងភារកិច្ចរបស់ គ.ក.ប/គ.ក.រ**

**ប្រការ ៩.៣.-**

គ.ក.ប/គ.ក.រ នីមួយៗមានភារកិច្ចចាត់ចែងគ្រប់គ្រង និងត្រួតពិនិត្យនូវរាល់កិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅក្នុងការិយាល័យបោះឆ្នោតដែល គ.ក.ប/គ.ក.រ នោះ ទទួលខុសត្រូវ ។

៩.៣.១ ប្រធាន គ.ក.ប/គ.ក.រ មានភារកិច្ចចាត់ចែង និងគ្រប់គ្រងនូវរាល់កិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត ដែលខ្លួនទទួលខុសត្រូវ និងត្រូវ ៖

៩.៣.១.១ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

៩.៣.១.២ ម្ចាស់ការក្នុងការអនុវត្តគ្រប់ដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ស្របតាម ច.ប.ឃ.ស ប.ន.ឃ.ស និងការណែនាំរបស់ គ.ជ.ប ។

៩.៣.១.៣ ទទួលពិនិត្យ ផ្ទៀងផ្ទាត់ និងការពារឱ្យបានហ្មត់ចត់នូវរាល់សម្ភារ ឯកសារ សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ពិសេសពិនិត្យលេខកូដនៃកញ្ចប់សន្លឹកឆ្នោតដើម្បីឱ្យ ប្រាកដថាជាសន្លឹកឆ្នោតសម្រាប់ឃុំ សង្កាត់ ។

៩.៣.១.៤ បោះទីតាំង រៀបចំការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត តាមគំរូប្លង់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងបំពាក់គ្រឿងសង្ហារិម ។

៩.៣.១.៥ តាមដាន និងត្រួតពិនិត្យការបំពេញការងាររបស់ សមាសភាព គ.ក.ប/គ.ក.រ នៅថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត ក្នុងអាណត្តិរបស់ខ្លួន ។

៩.៣.១.៦ ដាក់ជំនួសតំណែងសមាជិក គ.ក.ប/គ.ក.រ ណាដែលមិនបានមកបំពេញការងារបោះឆ្នោតតាមកិច្ចសន្យា ដោយយោងទៅតាមចំណុច ៩.៤.៩ នៃជំពូកនេះ ។

៩.៣.១.៧ ចាត់ចែង និងត្រួតពិនិត្យកិច្ចប្រតិបត្តិការបោះឆ្នោតក្នុងការិយាល័យបោះឆ្នោត ។ ក្នុងពេលកំពុងដំណើរការបោះឆ្នោត យ៉ាងយូរ ០១ (មួយ) ម៉ោងម្តង ត្រូវចូលក្នុងបន្ទប់សម្ងាត់ ដើម្បីត្រួតពិនិត្យសុវត្ថិភាពសម្ភារដែលបំពាក់នៅទីនោះ និងសណ្តាប់ធ្នាប់ ក្នុងករណីគ្មានអ្នកបោះឆ្នោតនៅក្នុងបន្ទប់សម្ងាត់ ។

៩.៣.១.៨ ធានាឱ្យប្រាកដថា គ្រប់កំណត់ហេតុ និងទម្រង់បែបបទទាំងអស់ ពាក់ព័ន្ធនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតត្រូវបានបំពេញ និងចុះហត្ថលេខាត្រឹមត្រូវ និងអញ្ជើញភ្នាក់ងារគណបក្សនយោបាយចុះហត្ថលេខា ជាសាក្សី ។

៩.៣.១.៩ ចាត់ចែងចែកកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតជូនភ្នាក់ងារគណបក្សនយោបាយដែលមានវត្តមាន ។

៩.៣.១.១០ ត្រួតពិនិត្យលិខិតតែងតាំង និងទទួលស្គាល់ភ្នាក់ងារគណបក្សនយោបាយ និងលិខិតតែងតាំង និងទទួលស្គាល់អ្នកសង្កេតការណ៍ដែលត្រូវចូលរួមសង្កេតមើលការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

៩.៣.១.១១ អនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ផ្លាស់ប្តូរទីកន្លែងពិនិត្យមើលដំណើរការបោះឆ្នោត ។

៩.៣.១.១២ ត្រួតពិនិត្យ និងបង្ហាញហិបឆ្នោត ដល់អ្នកដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត ។

៩.៣.១.១៣ បើក និងបិទកិច្ចប្រតិបត្តិការបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត ។

៩.៣.១.១៤ ធានារបៀបរៀបរយក្នុង និងក្រៅបរិវេណការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៩.៣.១.១៥ ចាក់ ឬកាត់ផ្តាច់សោឃ្លុំការពារហិបឆ្នោត ។

៩.៣.១.១៦ ធានាឱ្យប្រាកដថា អ្នកបោះឆ្នោតម្នាក់ៗ ត្រូវបានបង្រៀនឱ្យចេះពីរបៀបបោះឆ្នោត និងតាមដានពិនិត្យមើល ដើម្បីឱ្យប្រាកដថានៅពេលចេញពីបន្ទប់សម្ងាត់ អ្នកបោះឆ្នោតបានបត់សន្លឹកឆ្នោតតាមផ្នត់ដើមដូចការណែនាំ ។

៩.៣.១.១៧ ធានាឱ្យប្រាកដថា ការប្រើប្រាស់ទឹកខ្មៅលុបមិនជ្រះ ត្រូវតែបានអនុវត្តតាមការណែនាំ ។

៩.៣.១.១៨ ធានាឱ្យប្រាកដថា ការលើកយោបល់ជំទាស់ និងការប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់ក្នុងការិយាល័យបោះឆ្នោត ដោយភ្នាក់ងារគណបក្សនយោបាយ ស្របតាមមាត្រា ៩៤ នៃ ច.ប.ឃ.ស ត្រូវបានដោះស្រាយភ្លាម ដោយអនុវត្តស្របតាម ប.ន.ឃ.ស និងការណែនាំរបស់ គ.ជ.ប ។

៩.៣.១.១៩ ជួយអ្នកបោះឆ្នោតជាជនពិការដែលមិនអាចបោះឆ្នោតដោយខ្លួនឯងបានតាមការស្នើសុំរបស់សាមីខ្លួន ។

៩.៣.១.២០ ចាត់ចែង និងត្រួតពិនិត្យកិច្ចប្រតិបត្តិការផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោត ។

៩.៣.១.២១ ត្រួតពិនិត្យសុពលភាពសន្លឹកឆ្នោត និងប្រកាសឈ្មោះគណបក្សនយោបាយ ដែលបានទទួលសំឡេងឆ្នោត ។

៩.៣.១.២២ ប្រគល់ជូន គឃ.សប នូវកំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀត ។

៩.៣.១.២៣ ប្រគល់ជូន គឃ.សប នូវកំណត់ហេតុស្តីពីការបោះឆ្នោត និងហិបឆ្នោតដែលមានសន្លឹកឆ្នោតខាងក្នុង ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀត ក្នុងកាលៈទេសៈមានអាសន្ន ដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតបាន ។

៩.៣.១.២៤ បំពេញភារកិច្ចរបស់ខ្លួនក្នុងជំហរអព្យាក្រឹត និងមិនលម្អៀង ។

៩.៣.១.២៥ បំពេញភារកិច្ចផ្សេងៗទៀតដែល គឃ.សប តម្រូវឱ្យធ្វើ ។

៩.៣.២ អនុប្រធាន គ.ក.ប/គ.ក.រ ត្រូវជួយប្រធាន និងមានភារកិច្ចដោយឡែកដូចខាងក្រោម ៖

៩.៣.២.១ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៩.៣.២.២ ម្ចាស់ការក្នុងការអនុវត្តគ្រប់ដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ស្របតាម ច.ប.ឃ.ស ប.ន.ឃ.ស និងការណែនាំរបស់ គ.ជ.ប ។

៩.៣.២.៣ ជំនួសតំណែងប្រធាន ក្នុងករណីប្រធានមិនអាចមកបំពេញការងារបាន។

៩.៣.២.៤ រាប់ចំនួនសន្លឹកឆ្នោត ដែលបានទទួលជាក់ស្តែង សម្រាប់ប្រើក្នុងការិយាល័យបោះឆ្នោតមុននឹងបើកកិច្ចប្រតិបត្តិការបោះឆ្នោត ។

៩.៣.២.៥ ហែកសន្លឹកឆ្នោតផ្តាច់ចេញពីគល់បញ្ជីសៀវភៅសន្លឹកឆ្នោត បោះត្រាសម្ងាត់លើផ្នែកខាងខ្នង និងបត់ជា ០៤ (បួន) ផ្ទត់តាមការណែនាំរបស់ គ.ជ.ប រួចប្រគល់ជូនអ្នកបោះឆ្នោត ។

៩.៣.២.៦ ផ្តល់ការណែនាំស្តីពីនីតិវិធីនៃការបោះឆ្នោតដល់អ្នកបោះឆ្នោត។

៩.៣.២.៧ អនុញ្ញាតឱ្យអ្នកបោះឆ្នោតចូលគូសសន្លឹកឆ្នោតក្នុងបន្ទប់សម្ងាត់ នៅពេល ដែលបន្ទប់សម្ងាត់នោះទំនេរ គ្មានអ្នកបោះឆ្នោតផ្សេងទៀត ។

៩.៣.២.៨ ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតនៅពេលបញ្ចប់ការបោះឆ្នោត។

៩.៣.២.៩ ត្រួតពិនិត្យ និងបែងចែកតាមពំនូកសន្លឹកឆ្នោតមានត្រាសម្ងាត់ ឬគ្មានត្រាសម្ងាត់នៅខាងខ្នង មុននឹងប្រគល់ជូនប្រធាន ។

៩.៣.២.១០ កត់ត្រាសំឡេងឆ្នោត ដែលគណបក្សនយោបាយនីមួយៗ បានទទួលនៅលើតារាងកត់ត្រាសំឡេងឆ្នោត ។

៩.៣.២.១១ អមដំណើរប្រធាន ក្នុងការបញ្ជូន និងប្រគល់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ព្រមទាំង សម្ភារឯកសារបោះឆ្នោតផ្សេងទៀតជូន គឃ.សប ។

៩.៣.២.១២ បំពេញភារកិច្ចផ្សេងទៀត ដែល គឃ.សប និងប្រធាន គ.ក.ប/គ.ក.រ តម្រូវឱ្យធ្វើ ។

៩.៣.៣ លេខាធិការនៃ គ.ក.ប ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន និងជាអ្នកទទួលបន្ទុកការពិនិត្យភាពត្រឹមត្រូវនៃអ្នកបោះឆ្នោត ព្រមទាំងការបំពេញទម្រង់បែបបទទាក់ទងនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ហើយត្រូវ ៖

៩.៣.៣.១ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៩.៣.៣.២ ម្ចាស់ការក្នុងការអនុវត្តគ្រប់ដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ស្របតាម ច.ប.ឃ.ស ប.ន.ឃ.ស និងការណែនាំរបស់ គ.ជ.ប ។

៩.៣.៣.៣ ជួយប្រធានក្នុងការគ្រប់គ្រងសម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៩.៣.៣.៤ ជួយប្រធានក្នុងការរៀបចំការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតតាមគំរូប្លង់ ដែលកំណត់ដោយ គ.ជ.ប ។

៩.៣.៣.៥ ត្រួតពិនិត្យរកមើលស្នាមទឹកខ្មៅលុបមិនជ្រះនៅលើម្រាមដៃអ្នកបោះឆ្នោត ដើម្បីឱ្យបានដឹងថា គាត់បានបោះឆ្នោតហើយ ឬមិនទាន់បោះឆ្នោត នៅមុនពេលពិនិត្យឈ្មោះរបស់គាត់នៅក្នុងបញ្ជីបោះឆ្នោត ។

៩.៣.៣.៦ សួរបញ្ជាក់ឈ្មោះ ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ភាពដូចគ្នារវាងរូបពិត ឈ្មោះ និងទិន្នន័យ ក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ឬ ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ) សាមីអ្នកបោះឆ្នោតជាមួយនឹងរូបថត ឈ្មោះ និងទិន្នន័យក្នុងបញ្ជីបោះឆ្នោត រួចគូសសម្គាល់ថា បានមកបោះឆ្នោត ក្នុងកូនប្រអប់បួនជ្រុងទន្ទឹមនឹងឈ្មោះអ្នកបោះឆ្នោតនោះលើបញ្ជីបោះឆ្នោត ។

៩.៣.៣.៧ រាប់គំនូសសញ្ញាលើបញ្ជីបោះឆ្នោត និងរាយការណ៍ជូនប្រធានអំពីចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត និងមិនបានបោះឆ្នោត ។

៩.៣.៣.៨ បំពេញកំណត់ហេតុនៃការបោះឆ្នោត និងដាក់ជូនប្រធានចុះហត្ថលេខា រួចដាក់បង្ហាញឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពិនិត្យមើល ។

៩.៣.៣.៩ កត់ត្រាក្នុងកំណត់ហេតុនូវរាល់ការលើកយោបល់តវ៉ា ឬជំទាស់ ឬករណីប្ដឹងតវ៉ា និងប្ដឹងជំទាស់ទាក់ទងនឹងការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៩.៣.៣.១០ កត់ត្រាសំឡេងឆ្នោត ដែលគណបក្សនយោបាយនីមួយៗបានទទួលនៅលើតារាងកត់ត្រាសំឡេងឆ្នោត ។

៩.៣.៣.១១ បំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងដាក់ជូនប្រធានចុះហត្ថលេខា ។

៩.៣.៣.១២ បំពេញភារកិច្ចផ្សេងទៀត ដែល គឃ.សប និងប្រធាន គ.ក.ប/គ.ក.រ តម្រូវឱ្យធ្វើ ។

៩.៣.៤ សមាជិកទី ១ នៃ គ.ក.ប ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន និងត្រូវបំពេញភារកិច្ចដូចខាងក្រោម ៖

៩.៣.៤.១ ចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៩.៣.៤.២ ជួយប្រធានក្នុងការគ្រប់គ្រងសម្ភារ ឯកសារបោះឆ្នោត ។

៩.៣.៤.៣ ជួយប្រធានក្នុងការរៀបចំការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតតាមគំរូប្លង់ដែលកំណត់ដោយ គ.ជ.ប ។

៩.៣.៤.៤ ត្រួតពិនិត្យហិបឆ្នោត និងការស៊កសន្លឹកឆ្នោតចូលក្នុងហិបឆ្នោតក្នុងពេលកំពុងដំណើរការបោះឆ្នោត ។

៩.៣.៤.៥ រាយការណ៍ជូនប្រធាន ក្នុងករណីពិនិត្យឃើញថា អ្នកបោះឆ្នោតណាម្នាក់បានស៊កសន្លឹកឆ្នោតក្លែងក្លាយ ឬវត្ថុផ្សេងទៀត ចូលក្នុងហិបឆ្នោត ។

៩.៣.៤.៦ ជ្រលក់ម្រាមដៃរបស់អ្នកបោះឆ្នោត ដែលបានបោះឆ្នោតរួច ទៅក្នុងទឹកខ្មៅលុបមិនជ្រះឱ្យដល់គល់ក្រចក និងណែនាំគាត់ឱ្យរង់ចាំ៣០វិនាទីដើម្បីឱ្យទឹកខ្មៅស្ងួត មុននឹងចេញពីការិយាល័យបោះឆ្នោត ។

៩.៣.៤.៧ រាប់ចំនួនសន្លឹកឆ្នោតដែលចាក់ចេញពីហិបឆ្នោត ដើម្បីផ្ទៀងផ្ទាត់ទៅនឹងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត និងដកយកវត្ថុមិនមែនជាសន្លឹកឆ្នោត (ប្រសិនបើមាន) ដាក់ទៅក្នុងស្រោមសំបុត្រដោយឡែក។

៩.៣.៤.៨ លាសន្លឹកឆ្នោតដែលចាក់ចេញពីហិបឆ្នោត ដើម្បីត្រួតពិនិត្យស្នាមត្រាសម្ងាត់នៅផ្នែកខាងខ្នង និងបែងចែកតាមពំនូកសន្លឹកឆ្នោតមានត្រាសម្ងាត់ ឬគ្មានត្រាសម្ងាត់ ។

៩.៣.៤.៩ កត់ត្រាសំឡេងឆ្នោត ដែលគណបក្សនយោបាយនីមួយៗបានទទួលនៅផ្ទាំងក្រដាសធំ ។

៩.៣.៤.១០ បំពេញភារកិច្ចផ្សេងទៀតដែល គឃ.សប និងប្រធាន គ.ក.ប/គ.ក.រ តម្រូវឱ្យធ្វើ ។

៩.៣.៥ សមាជិកទី ២ នៃ គ.ក.ប/គ.ក.រ ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន និងត្រូវបំពេញភារកិច្ចដូចខាងក្រោម ៖

៩.៣.៥.១ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៩.៣.៥.២ ជួយប្រធានក្នុងការរៀបចំការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតតាមគំរូប្លង់ ដែលកំណត់ដោយ គ.ជ.ប ។

៩.៣.៥.៣ ជួយរកឈ្មោះអ្នកបោះឆ្នោត នៅក្នុងបញ្ជីបោះឆ្នោតដែលបិទនៅខាងក្រៅការិយាល័យបោះឆ្នោត និងប្រាប់លេខរៀងឈ្មោះរបស់គាត់ ។

៩.៣.៥.៤ ចាត់ចែង និងថែរក្សារបៀបរៀបរយជូនអ្នកបោះឆ្នោត (ក្នុងករណីចាំបាច់ អាចផ្តល់បណ្ណលេខរៀងតាមលំដាប់អ្នកមកមុនមកក្រោយ ) ព្រមទាំងរាយការណ៍ជូនប្រធាន អំពីការរំខាន ឬការអុកឡុកនានាក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត (ប្រសិនបើមាន) ។

៩.៣.៥.៥ រាយការណ៍ជូនប្រធាន ក្នុងករណីពិនិត្យឃើញថា មានអ្នកបោះឆ្នោតណាម្នាក់បានយកសន្លឹកឆ្នោតផ្លូវការចេញពីការិយាល័យបោះឆ្នោត ។

៩.៣.៥.៦ ប្រមូល អ.ខ ឬ ឯ.អ ពីអ្នកបោះឆ្នោត ដែលស្ថិតក្នុងបរិវេណខាង ក្នុងនៃការិយាល័យបោះឆ្នោត នៅពេលដល់ម៉ោងបញ្ចប់ការបោះឆ្នោតម៉ោង ១៥:០០ (ដប់ប្រាំ) រសៀល (ប្រសិនបើមាន) ។

៩.៣.៥.៧ ចោះ ឬកាត់សន្លឹកឆ្នោត ដែលនៅសល់មិនបានប្រើប្រាស់ បន្ទាប់ពីបញ្ចប់ការផ្ទៀងផ្ទាត់សន្លឹកឆ្នោត ។

៩.៣.៥.៨ សហការជាមួយសមាជិកទី ៣ ក្នុងការការពារមាត់ទ្វារការិយាល័យបោះឆ្នោត ការថែរក្សាសម្ភារ ឯកសារបោះឆ្នោត និងចាត់ចែងសណ្តាប់ធ្នាប់ក្នុងការិយាល័យរាប់សន្លឹកឆ្នោត ។

៩.៣.៥.៩ បិទផ្សាយកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ។

៩.៣.៥.១០ បំពេញភារកិច្ចផ្សេងទៀតដែល គឃ.សប និងប្រធាន គ.ក.ប/គ.ក.រ តម្រូវឱ្យធ្វើ ។

៩.៣.៦ សមាជិកទី ៣ នៃ គ.ក.ប/គ.ក.រ ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន និងត្រូវបំពេញភារកិច្ចដូចខាងក្រោម ៖

៩.៣.៦.១ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៩.៣.៦.២ ជួយប្រធានក្នុងការគ្រប់គ្រងសម្ភារ ឯកសារបោះឆ្នោត ។

៩.៣.៦.៣ ជួយប្រធានក្នុងការរៀបចំការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតតាមគំរូប្លង់ ដែលកំណត់ដោយ គ.ជ.ប ។

៩.៣.៦.៤ ត្រួតពិនិត្យច្រកទ្វារចូលនៃការិយាល័យបោះឆ្នោត ណែនាំអ្នកបោះឆ្នោតឱ្យឈរបន្តគ្នាជាជួរ តាមលំដាប់មុនក្រោយ ប្រសិនបើគាត់ត្រូវបោះឆ្នោតនៅការិយាល័យបោះឆ្នោតនេះ និងត្រួតពិនិត្យ អ.ខ ឬ ឯ.អ របស់គាត់ ។

៩.៣.៦.៥ អនុញ្ញាតឱ្យអ្នកបោះឆ្នោតមានវត្តមានក្នុងការិយាល័យបោះឆ្នោត ចំនួន ០៤ នាក់ ក្នុងពេលតែមួយ ។

៩.៣.៦.៦ ផ្តល់អាទិភាពចូលក្នុងការិយាល័យបោះឆ្នោត ចំពោះអ្នកបោះឆ្នោតជាព្រះសង្ឃ មនុស្សចាស់ជរា ស្ត្រីមានផ្ទៃពោះ ស្ត្រីមានកូនតូច ជនពិការ និងអ្នកមានជំងឺ បន្ទាប់មកគឺអ្នកឈរខាងមុខគេក្នុងជួរ ។

៩.៣.៦.៧ ត្រួតពិនិត្យស្នាមទឹកខ្មៅលុបមិនជ្រះនៅលើម្រាមដៃអ្នកបោះឆ្នោត ដើម្បីឱ្យបានដឹងថា គាត់បានបោះឆ្នោតហើយ ឬមិនទាន់បានបោះឆ្នោត ។

៩.៣.៦.៨ ជួយចាត់ចែង និងថែរក្សារបៀបរៀបរយក្នុងការិយាល័យបោះឆ្នោត និងរាយការណ៍អំពីការអុកឡុករំខានជូនប្រធាន ។

៩.៣.៦.៩ សហការជាមួយសមាជិកទី ២ ក្នុងការការពារសន្តិសុខនៅច្រកផ្លូវចូលការិយាល័យបោះឆ្នោត ថែរក្សាសម្ភារ ឯកសារបោះឆ្នោត និងចាត់ចែងសណ្តាប់ធ្នាប់នៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត។

៩.៣.៦.១០ បំពេញភារកិច្ចផ្សេងទៀតដែល គឃ.សប និងប្រធាន គ.ក.ប/គ.ក.រ តម្រូវឱ្យធ្វើ ។

**ការត្រៀមសម្ភារ ឯកសារបោះឆ្នោត និងការត្រួតពិនិត្យទីតាំងការិយាល័យបោះឆ្នោត**

**ប្រការ ៩.៤.-**

គ.ជ.ប ត្រូវធានាថា រាល់សម្ភារ ឯកសារបោះឆ្នោត ត្រូវតែបានបញ្ជូន និងប្រគល់ជូន គ.ក.ប មិនឱ្យលើសពី ៣៦ (សាមសិបប្រាំមួយ) ម៉ោងមុនថ្ងៃបោះឆ្នោត ។ នៅពេលព្រឹកនៃថ្ងៃមុនថ្ងៃបោះឆ្នោត ប្រធាន គ.ក.ប ត្រូវកោះប្រជុំសមាសភាពទាំងអស់នៃ គ.ក.ប ឱ្យមកបង្ហាញខ្លួននៅទីតាំងការិយាល័យបោះឆ្នោត ដើម្បីធ្វើការត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត និងរៀបចំគំរូប្លង់ការិយាល័យបោះឆ្នោត ។

៩.៤.១ គ.ជ.ប ត្រូវផ្គត់ផ្គង់សម្ភារ ឯកសារគ្រប់គ្រាន់ សម្រាប់បម្រើកិច្ចប្រតិបត្តិការនៃការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោត ជូន គធ.ខប គឃ.សប និង គ.ក.ប ទាំងអស់ ។

៩.៤.២ នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត ត្រូវទទួលខុសត្រូវក្នុងការផលិតបញ្ជីបោះឆ្នោតផ្លូវការចំនួន ០៤ (បួន)ច្បាប់ ក្នុងការិយាល័យបោះឆ្នោតនីមួយៗ សម្រាប់បែងចែកជូន គឃ.សប និង គ.ក.ប ដើម្បីប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

៩.៤.៣ នាយកដ្ឋានប្រតិបត្តិការ ត្រូវរៀបចំផែនការបែងចែក និងត្រៀមសម្ភារ ឯកសារសម្រាប់ដឹកជញ្ជូនទៅកាន់គោលដៅនានាដើម្បីបម្រើការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ឱ្យបានគ្រប់គ្រាន់ជាមុន ។ សម្ភារ ឯកសារសម្រាប់បម្រើការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោតត្រូវបានរៀបចំដាក់ក្នុងហិប ដែលរួមមាន ៤ប្រភេទ គឺ ៖

៩.៤.៣.១ ហិបបរិក្ខារសម្រាប់បណ្តុះបណ្តាលដែលត្រូវបញ្ជូន និងប្រគល់ជូននាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោត និង គធ.ខប ។

៩.៤.៣.២ ហិបបរិក្ខារ គធ.ខប ដែលអាចមានមួយ ឬច្រើន ហើយត្រូវបញ្ជូន និងប្រគល់ជូន គធ.ខប ។

៩.៤.៣.៣ ហិបបរិក្ខារ គឃ.សប ដែលអាចមានមួយ ឬច្រើន ហើយត្រូវបញ្ជូន និងប្រគល់ជូន គឃ.សប ។

៩.៤.៣.៤ ហិបបរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលត្រូវបញ្ជូន និងប្រគល់ជូន គ.ក.ប/គ.ក.រ ។

៩.៤.៤ នៅរាល់ពេលនៃការបញ្ជូន និងប្រគល់ ទទួលហិបបរិក្ខារ ដូចបានចែងក្រោមចំណុច ៩.៤.៣ ខាងលើ មន្ត្រីដែលទទួលបន្ទុកការបញ្ជូននៅតាមថ្នាក់នីមួយៗ ត្រូវបំពេញលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) និងត្រូវឱ្យមន្ត្រីដែលទទួលបន្ទុកការទទួលនៅតាមថ្នាក់នីមួយៗ ចុះហត្ថលេខា បញ្ជាក់ថាបានទទួលគ្រប់ចំនួនហើយ ។

៩.៤.៥ ហិបបរិក្ខារ គធ.ខប ដែលត្រូវបញ្ជូន និងប្រគល់ជូន គធ.ខប សម្រាប់ប្រើប្រាស់ក្នុងដំណើរការបោះឆ្នោត ដូចមានក្នុងឧបសម្ព័ន្ធទី ៦ ។

៩.៤.៦ ហិបបរិក្ខារ គឃ.សប ដែលត្រូវបញ្ជូន និងប្រគល់ជូន គឃ.សប សម្រាប់ប្រើប្រាស់ក្នុងដំណើរការបោះឆ្នោតទាំងមូល ដូចមានក្នុងឧបសម្ព័ន្ធទី ៧ ។

៩.៤.៧ ហិបបរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងកញ្ចប់សម្ភារ ឧបករណ៍ និងឯកសារផ្សេងទៀត ដូចមានក្នុងឧបសម្ព័ន្ធទី ៨ ដែល គឃ.សប ត្រូវបញ្ជូន និងប្រគល់ជូន គ.ក.ប នីមួយៗ មិនឱ្យលើសពី ៣៦ (សាមសិបប្រាំមួយ) ម៉ោង មុនថ្ងៃបោះឆ្នោត ។

៩.៤.៨ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវធានាក្នុងការបញ្ជូន និងប្រគល់ឱ្យបានគ្រប់គ្រាន់ជូន គ.ក.ប/គ.ក.រ នៅមួយថ្ងៃមុនថ្ងៃបោះឆ្នោតនូវសម្ភារ ឯកសារបោះឆ្នោតដូចចែងក្នុងចំណុច ៩.៤.៧ ខាងលើ ។ គឃ.សប ត្រូវជូនដំណឹងដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដើម្បីចូលរួមសង្កេតមើល គ.ក.ប/គ.ក.រ នៅពេលធ្វើការត្រួតពិនិត្យឡើងវិញនូវសម្ភារ ឯកសារបោះឆ្នោត ដូចចែងក្នុងចំណុច ៩.៤.១០ ខាងក្រោម ។

៩.៤.៩ សមាសភាពទាំងអស់នៃ គ.ក.ប/គ.ក.រ ត្រូវតែមកបង្ហាញខ្លួនតាមការកោះអញ្ជើញរបស់ប្រធាន គ.ក.ប/គ.ក.រ និងត្រូវធានាថា នឹងមានវត្តមានក្នុងការបំពេញការងារនៅថ្ងៃបោះឆ្នោត ។

៩.៤.៩.១ មុនថ្ងៃបោះឆ្នោត ២៤(ម្ភៃបួន)ម៉ោង ប្រធាន គ.ក.ប ត្រូវប្រជុំមន្ត្រីទាំងអស់ ដើម្បីពិនិត្យវត្តមាន និងពិនិត្យទីតាំងការិយាល័យបោះឆ្នោត និងពិនិត្យសម្ភារ បរិក្ខារបម្រើឱ្យការបោះឆ្នោត ។ ក្នុងករណីបើមានមន្ត្រីណាម្នាក់អវត្តមាន មន្ត្រីនោះត្រូវជំនួសដោយមន្ត្រីថ្មីដែលជ្រើសតាំងឡើងតាមការសម្រេចរបស់ គឃ.សប ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ។

៩.៤.៩.២ ប្រសិនបើសមាសភាពណាម្នាក់នៃ គ.ក.ប/គ.ក.រ មិនអាចបំពេញការងារក្នុងថ្ងៃបោះឆ្នោត ប្រធានត្រូវតែជូនដំណឹងដល់ គឃ.សប ជាបន្ទាន់ ដើម្បីដាក់អ្នកជំនួស ។

៩.៤.៩.៣ ប្រសិនបើប្រធាន មិនអាចមកបំពេញការងារបាន ដោយសារមូលហេតុសំខាន់ណាមួយនោះ អនុប្រធានត្រូវចូលកាន់តំណែងប្រធាន ហើយសមាជិកទី ១ ចូលកាន់តំណែងអនុប្រធាន ចំណែកអ្នកដែលត្រូវជ្រើសរើសថ្មីចេញពីក្នុងចំណោមប្រជាពលរដ្ឋដែលបានដាក់ពាក្យប្រឡង ត្រូវចូលកាន់តំណែងជំនួសសមាជិកទី ១ ។

៩.៤.៩.៤ ប្រសិនបើអនុប្រធាន មិនអាចមកធ្វើការបាននោះ ត្រូវតែងតាំងសមាជិកទី ១ ជាអនុប្រធាន ហើយអ្នកដែលត្រូវជ្រើសរើសថ្មី នឹងកាន់តំណែងជាសមាជិកទី ១ ។

៩.៤.៩.៥ ប្រសិនបើលេខាធិការ មិនអាចមកធ្វើការបាន ត្រូវតែងតាំងសមាជិកទី១ ជាលេខាធិការ ហើយអ្នកដែលត្រូវជ្រើសរើសថ្មី នឹងកាន់តំណែងជាសមាជិកទី ១ ។

៩.៤.៩.៦ សមាសភាពទាំងអស់នៃ គ.ក.ប/គ.ក.រ រួមទាំងអ្នកដែលទើបតែជ្រើសរើសថ្មី ត្រូវរួមគ្នាសិក្សាឡើងវិញ នូវនីតិវិធីនៃការបោះឆ្នោត និងសៀវភៅណែនាំ គ.ក.ប/គ.ក.រ ។

៩.៤.៩.៧ អ្នកតែងតាំងថ្មីទាំងអស់ត្រូវតែបានទទួលការបណ្តុះបណ្តាល និងអនុវត្តដូចចែងក្នុងចំណុច ៩.៤.៩.៦ ខាងលើ ។

៩.៤.៩.៨ ប្រធាន គ.ក.ប/គ.ក.រ ត្រូវតែជូនដំណឹងជាបន្ទាន់ដល់ គឃ.សប អំពីអ្វីដែលបានអនុវត្ត ពាក់ព័ន្ធនឹងការដាក់ជំនួសតំណែងណាមួយនៃ គ.ក.ប/គ.ក.រ ។

៩.៤.១០ បន្ទាប់ពីអនុវត្តចំណុច ៩.៤.៩ រួច គ.ក.ប ត្រូវធ្វើការត្រួតពិនិត្យឡើងវិញនូវ សម្ភារ ឯកសារបោះឆ្នោតទាំងអស់ដែល គ.ក.ប បានទទួល ហើយដែលមានរាយមុខក្នុង លិខិតបញ្ជូន និងប្រគល់ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ។

៩.៤.១០.១ គ.ក.ប ត្រូវធ្វើការត្រួតពិនិត្យឡើងវិញនូវរាល់សម្ភារ ឯកសារបោះឆ្នោត ដោយប្រើតារាងត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត (ទ.១១១២) ។

៩.៤.១០.២ ប្រសិនបើសម្ភារ ឯកសារបោះឆ្នោតដែលបានទទួលមានចំនួនគ្រប់គ្រាន់ហើយ សមាសភាពទាំងអស់នៃ គ.ក.ប ត្រូវចុះហត្ថលេខា លើតារាងត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត (ទ.១១១២) ។

៩.៤.១០.៣ ប្រសិនបើសម្ភារ ឯកសារបោះឆ្នោតណាមួយ ឬច្រើនដែលបានទទួលនោះមិនមានចំនួនគ្រប់គ្រាន់ លេខាធិការ ត្រូវបំពេញត្រង់ផ្នែកសម្ភារ ឯកសារបោះឆ្នោតដែលបាត់បង់ នៅលើតារាងត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត (ទ.១១១២) ហើយត្រូវផ្ញើតារាងត្រួតពិនិត្យនេះ ០១ (មួយ) ច្បាប់ ជាបន្ទាន់ទៅ គឃ.សប ។

៩.៤.១០.៤ ប្រសិនបើ សម្ភារ ឯកសារដែលបាត់បង់ទៅនោះ ជាសម្ភារ ឯកសារសំខាន់សម្រាប់ការបោះឆ្នោត ប្រធាន គ.ក.ប ត្រូវចាត់សមាជិក ០២ (ពីរ)រូប ឱ្យធ្វើដំណើរទៅទីស្នាក់ការ គឃ.សប ដើម្បីទទួលសម្ភារ ឯកសារថ្មីជំនួសសម្ភារ ឯកសារដែលខ្វះ ឬបានបាត់បង់ទៅ លើកលែងតែមានវិទ្យុទាក់ទង ឬទូរស័ព្ទដែលអាចបញ្ជូនព័ត៌មានស្នើសុំ គឃ.សប ដោះស្រាយបញ្ហាខាងលើបាន ។

៩.៤.១០.៥ ក្នុងការត្រួតពិនិត្យឡើងវិញ នូវសម្ភារ ឯកសារបោះឆ្នោតខាងលើនេះ គ.ក.ប ត្រូវយកចិត្តទុកដាក់ចំពោះមុខសម្ភារដូចខាងក្រោម ៖

- ពិនិត្យកញ្ចប់សន្លឹកឆ្នោតឱ្យប្រាកដថា ជាកញ្ចប់សន្លឹកឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតនៃឃុំ សង្កាត់នោះ ហើយគ្រាន់តែពិនិត្យផ្ទៀងផ្ទាត់ចំនួន និងលេខរៀងដែលបានកត់ត្រានៅលើកញ្ចប់សន្លឹកឆ្នោតប៉ុណ្ណោះ ដោយមិនត្រូវបើកកញ្ចប់សន្លឹកឆ្នោតជាដាច់ខាត ។
- ពិនិត្យស្រោមសំបុត្រដាក់ត្រាសម្ងាត់ឱ្យប្រាកដថា ពិតជាមានត្រាសម្ងាត់នៅខាងក្នុង ប៉ុន្តែមិនត្រូវបើកស្រោមសំបុត្រជាដាច់ខាត ។

៩.៤.១១ សម្ភារ ឯកសារសំខាន់ៗដែល គ.ក.ប មិនបានទទួល ហើយដែលអាចរាំងស្ទះដល់ការបើកការិយាល័យបោះឆ្នោត រួមមាន ៖

៩.៤.១១.១ សន្លឹកឆ្នោតមិនទាន់ប្រើប្រាស់ ។

៩.៤.១១.២ ត្រាសម្ងាត់ សម្រាប់បោះលើខ្នងសន្លឹកឆ្នោត ។

៩.៤.១១.៣ បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ។

៩.៤.១១.៤ ហិបឆ្នោត និងសោឃ្លុំមានលេខ ។

៩.៤.១១.៥ ទឹកខ្មៅលុបមិនជ្រះសម្រាប់ជ្រលក់ម្រាមដៃ សម្គាល់ថាបានបោះឆ្នោតហើយ ។

៩.៤.១២ សម្ភារ ឯកសារដទៃទៀត ដែលប្រសិនបើមិនបានផ្តល់ដោយ គឃ.សប នោះ គ.ក.ប ត្រូវច្នៃបង្កើតឡើង ឬដោះស្រាយដោយខ្លួនឯង ៖

៩.៤.១២.១ កន្ទេល ឬក្រដាសកាតុងក្រាស់ ឬរបស់ផ្សេងទៀតដែលអាចប្រើបិទបាំងជំនួសបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត ។

៩.៤.១២.២ ក្រដាសសម្រាប់សរសេរកំណត់ហេតុដោយដៃ ដែលអាចជំនួសទម្រង់បែបបទ សម្រាប់បំពេញកំណត់ហេតុជាគំរូ ។

៩.៤.១២.៣ ប៊ិកសរសេរ បន្ទាត់ កន្ត្រៃ ខ្សែចង... ។

៩.៤.១៣ នៅពេលដែលសម្ភារ ឯកសារបោះឆ្នោតមានគ្រប់ចំនួនហើយ ប្រធាន គ.ក.ប ត្រូវចាត់សមាជិកទី ២ ឱ្យបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការ ០១ (មួយ) ច្បាប់ នៅមុខទីតាំងការិយាល័យបោះឆ្នោត ។

៩.៤.១៤ បន្ទាប់ពីបានអនុវត្តចំណុច ៩.៤.១៣ រួច គ.ក.ប ត្រូវរៀបចំការិយាល័យ តាមគំរូប្លង់ការិយាល័យបោះឆ្នោតដើម្បីឱ្យប្រាកដថា ទីតាំងការិយាល័យបោះឆ្នោតនោះ អាចដំណើរការបោះឆ្នោតបានហើយដែលអាចរៀបចំឱ្យរួចស្រេចនៅម៉ោង៦:០០(ប្រាំមួយ)ព្រឹកនៃថ្ងៃបោះឆ្នោត ។

៩.៤.១៤.១ គ.ក.ប ត្រូវរៀបចំការិយាល័យបោះឆ្នោតតាមគំរូប្លង់ ឯកភាពគ្នាមួយដោយត្រូវគោរពតាមគោលការណ៍ ដូចបានចែងក្នុងសៀវភៅណែនាំ គ.ក.ប/គ.ក.រ ។

៩.៤.១៤.២ ប្រសិនបើ គ្មានគ្រឿងសង្ហារិមនៅក្នុងការិយាល័យបោះឆ្នោតទេ ប្រធាន ត្រូវធ្វើសំណើសុំខ្ចីពីអាជ្ញាធរមូលដ្ឋានជាបន្ទាន់នូវគ្រឿងសង្ហារិមចាំបាច់មួយចំនួនសម្រាប់បម្រើការបោះឆ្នោតដូចជា តុ កៅអី និងសម្ភារដទៃទៀត ដែលអាចសម្រួលដល់ការងារបោះឆ្នោត ។

៩.៤.១៤.៣ ប្រធាន ត្រូវស្នើសុំឱ្យមានកម្លាំងសន្តិសុខយាមកាម រក្សាសន្តិសុខទីតាំងការិយាល័យបោះឆ្នោត ហើយប្រសិនបើអាចធ្វើបាន ប្រធាន ត្រូវបិទទ្វារចាក់សោទីតាំងការិយាល័យបោះឆ្នោតនោះផង ។

៩.៤.១៥ ប្រធានរួមជាមួយសមាជិក គ.ក.ប ត្រូវរក្សាការពារសម្ភារ ឯកសារទាំងនោះឱ្យបានហ្មត់ចត់នៅមុនពេលបោះឆ្នោត ។

៩.៤.១៥.១ សម្ភារ ឯកសារបោះឆ្នោតអាចនឹងរក្សាទុកនៅផ្ទះរបស់ប្រធាន ឬសមាជិកណាម្នាក់ ឬនៅទីតាំងណាមួយដែល គ.ក.ប ឯកភាពគ្នាថាមានសុវត្ថិភាព ។

៩.៤.១៥.២ យ៉ាងហោចណាស់ត្រូវមានសមាជិក គ.ក.ប ០៣ (បី) នាក់ គិតទាំងប្រធានផងសម្រាកនៅផ្ទះ ឬទីតាំងដែលទទួលរក្សាសម្ភារ ឯកសារបោះឆ្នោត ដើម្បីរួមចំណែកក្នុងការថែរក្សាសុវត្ថិភាព ។

៩.៤.១៥.៣ ប្រធាន គ.ក.ប ត្រូវស្នើសុំឱ្យមានកម្លាំងសន្តិសុខ ដើម្បីរួមសហការការពារបរិវេណខាងក្រៅផ្ទះ ឬទីតាំងដែលទទួលរក្សាទុកសម្ភារ ឯកសារបោះឆ្នោត ។

៩.៤.១៦ ប្រធាន គ.ក.ប ត្រូវណាត់ជាមួយសមាជិកដទៃទៀតនៃ គ.ក.ប ឱ្យមកកាន់ផ្ទះ ឬទីតាំងសុវត្ថិភាពដែលទទួលរក្សាទុកសម្ភារ ឯកសារបោះឆ្នោតនៅម៉ោង ៥:៣០ (ប្រាំកន្លះ) ព្រឹកនៃថ្ងៃបោះឆ្នោតជាកំហិត ដើម្បីដឹកជញ្ជូនសម្ភារ ឯកសារបោះឆ្នោតទៅកាន់ទីតាំងការិយាល័យបោះឆ្នោត ។

៩.៤.១៧ សមាជិកទាំងអស់នៃ គ.ក.ប ត្រូវត្រៀមអាហារសម្រាប់រយៈពេល ០១ (មួយ) ថ្ងៃសម្រាប់ហូបនៅពេលទំនេរ ដែលពុំមានអ្នកបោះឆ្នោត ឬនៅពេលណាមួយសមស្រប ។

### ទីតាំងរដ្ឋបាល និងសន្តិសុខនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត

**ប្រការ ៩.៥.-**

ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតគឺជាទីតាំងរដ្ឋបាល និងសន្តិសុខ ដែលមានបរិវេណខាងក្នុង និងបរិវេណខាងក្រៅ ដូចចែងក្រោមប្រការ ៥.៥ ក្នុងជំពូកទី ៥ នៃបទបញ្ជា និងនីតិវិធីនេះ ។ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតត្រូវតែជាកន្លែងដែលមានការត្រួតពិនិត្យ និងយាមកាមយ៉ាងតឹងរ៉ឹងបំផុតក្នុងគោលបំណងនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៩.៥.១ ប្រធាន គ.ក.ប ឬប្រធាន គ.ក.រ ត្រូវចាត់វិធានការចាំបាច់នានា ដើម្បីការពារអ្នកនៅខាងក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ព្រមទាំងអ្នកនៅក្នុងបរិវេណខាងក្នុងការិយាល័យទាំងនោះ ឱ្យចៀសផុតពីការបង្កឱ្យមានរបួសស្នាម ការរំខានអុកឡុក ការបំភិតបំភ័យ ឬការគំរាមកំហែង និងរក្សាការពារសម្ភារ ឯកសារបោះឆ្នោតទាំងអស់នៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតទាំងនោះ ។

៩.៥.២ ចំពោះក្របខណ្ឌនៃការិយាល័យបោះឆ្នោត វិធានការ និងលក្ខខណ្ឌទាំងឡាយដែលបានចែងក្នុងប្រការ ៥.៦ និងក្រោមចំណុច ៥.៦.១ ៥.៦.២ ៥.៦.៣ ៥.៦.៥ ៥.៦.៧ និង ៥.៦.៨ ក្នុងជំពូកទី ៥ នៃ ប.ន.យ.ស នេះ ត្រូវតែបានអនុវត្ត ។

៩.៥.៣ ចំពោះក្របខណ្ឌនៃការិយាល័យរាប់សន្លឹកឆ្នោត វិធានការ និងលក្ខខណ្ឌទាំងឡាយដែលបានចែងក្នុងប្រការ ៥.៦ និងក្រោមចំណុច ៥.៦.១ ៥.៦.២ ៥.៦.៤ ៥.៦.៦ ៥.៦.៧ និង ៥.៦.៨ ក្នុងជំពូកទី ៥ នៃ ប.ន.យ.ស នេះ ត្រូវតែបានអនុវត្ត ។

### ការប្រព្រឹត្តទៅនៃការបោះឆ្នោត

**ប្រការ ៩.៦.-**

គ.ក.ប ត្រូវចូលដល់ទីតាំងការិយាល័យបោះឆ្នោត ដោយនាំមកជាមួយនូវសម្ភារ ឯកសារបោះឆ្នោត ឱ្យបានទាន់ពេលនៅម៉ោង ៦:០០ (ប្រាំមួយ) ព្រឹក នាថ្ងៃបោះឆ្នោតជាកំហិត ដើម្បីគ្រប់គ្រង និងចាត់ចែងការបោះឆ្នោត ។

៩.៦.១ បន្ទាប់ពី គ.ក.ប បានចូលដល់ក្នុងការិយាល័យបោះឆ្នោតភ្លាម ប្រធាន គ.ក.ប ត្រូវប្រកាសឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ចូលក្នុងការិយាល័យបោះឆ្នោត ដោយធ្វើការត្រួតពិនិត្យបណ្ណសម្គាល់ ឬ/និងសេចក្តីសម្រេចតែងតាំង និងទទួលស្គាល់ជាផ្លូវការម្នាក់ម្តងៗ រួចប្រាប់ទីកន្លែង ដែលបម្រុងទុកសម្រាប់ពួកគេ ដូចមានចែងក្នុងចំណុច ៩.៦.២.៥ ខាងក្រោម ។

៩.៦.២ ទន្ទឹមពេលអនុវត្តចំណុច ៩.៦.១ ខាងលើ ប្រធាន គ.ក.ប ត្រូវចាត់សមាជិកទី ២ ឱ្យទៅបំពេញមុខនាទីរបស់ខ្លួននៅបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត ព្រមទាំងត្រូវចាត់ចែងសមាជិកដទៃទៀតនៃ គ.ក.ប ឱ្យរៀបចំគ្រឿងសង្ហារិម និងដាក់សម្ភារ ឯកសារសម្រាប់ការបោះឆ្នោតដូចបានកំណត់ឯកភាពគ្នា លើគំរូប្លង់ការិយាល័យបោះឆ្នោត ដែលបានរៀបចំមុនមួយថ្ងៃ និងដូចបានបញ្ជាក់នៅក្នុងសៀវភៅណែនាំ គ.ក.ប ។

៩.៦.២.១ តុមួយដាក់នៅប៉ែកខាងឆ្វេងដៃ បន្ទាប់ពីផ្លូវចូលសម្រាប់ប្រធាន ដែលនៅលើនោះមានសម្ភារ ឯកសារបោះឆ្នោត និងទម្រង់បែបបទលេខ ១២០២ សម្រាប់បំពេញពាក្យបណ្តឹង ។

៩.៦.២.២ តុវែងមួយ ឬតុតូចពីរដាក់នៅប៉ែកខាងស្តាំដៃ បន្ទាប់ពីផ្លូវចូល សម្រាប់លេខាធិការ និងអនុប្រធានអង្គុយជាប់គ្នា ដែលនៅចំកន្លែងលេខាធិការមានដាក់បញ្ជីបោះឆ្នោត ត្រាការិយាល័យ ទម្រង់បែបបទ សម្រាប់បំពេញកំណត់ហេតុនៃការបោះឆ្នោត និងទម្រង់បែបបទផ្សេងទៀត ហើយនៅចំកន្លែងអនុប្រធានមានដាក់កញ្ចប់សន្លឹកឆ្នោត តាំប៉ុង និងស្រោមសំបុត្រដាក់ត្រាសម្ងាត់សម្រាប់បោះលើខ្នងសន្លឹកឆ្នោត ។

៩.៦.២.៣ បន្ទប់សម្ងាត់សម្រាប់បិទបាំងការគូសសន្លឹកឆ្នោតចំនួន ០២ (ពីរ) ដែលមានប៊ិកចងខ្សែភ្ជាប់ស្រាប់ ដាក់នៅលើតុពីរក្បែរជញ្ជាំងប្រមាណ ០១ (មួយ)ម៉ែត្រកន្លះពីជញ្ជាំង និងមានចម្ងាយពីគ្នាយ៉ាងតិច ០១(មួយ)ម៉ែត្រ ប៉ុន្តែមិនត្រូវដាក់នៅក្បែរបង្អួចទេ ។ ផ្ទាំងក្រដាស សម្រាប់ទ្រាប់គូសសន្លឹកឆ្នោត ០១ (មួយ) សន្លឹកត្រូវបិទភ្ជាប់ទៅនឹងផ្ទៃតុនៃបន្ទប់សម្ងាត់នីមួយៗ បន្ទប់សម្ងាត់ត្រូវមានពន្លឺគ្រប់គ្រាន់ ។

៩.៦.២.៤ ហិបឆ្នោត ទឹកខ្មៅលុបមិនជ្រះ និងកំណាត់សម្រាប់ជូត ដាក់នៅលើតុវែងមួយ ដែលស្ថិតនៅត្រង់កណ្តាលបន្ទប់ទល់មុខតុរបស់ប្រធាន សម្រាប់សមាជិកទី១ ។

៩.៦.២.៥ តុ និងកៅអីសម្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ (ប្រសិនបើមាន) ដាក់នៅអែបជញ្ជាំងប៉ែកខាងឆ្វេងដៃនៃតុរបស់ប្រធាន និងនៅក្រោយតុអនុប្រធាន និងលេខាធិការ ។

៩.៦.២.៦ ហិបបរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោតដែលមានសម្ភារ ឯកសារមិនទាន់ត្រូវប្រើប្រាស់រក្សាទុកនៅក្បែរតុប្រធាន ។

៩.៦.៣ ពេលអនុវត្តចំណុច ៩.៦.១ និង ៩.៦.២ រួចរាល់ ប្រធានត្រូវពន្យល់ណែនាំជារួម ដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានា ដោយសង្ខេបអំពីខ្លឹមសារសំខាន់ៗ ដែលត្រូវអនុវត្តដូចខាងក្រោម ៖

៩.៦.៣.១ ត្រូវគោរព ច.ប.ឃ.ស ប.ន.ឃ.ស ក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយក្នុងដំណើរការបោះឆ្នោត ក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោតក្នុងដំណើរការបោះឆ្នោត និងក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត ដែលកំណត់ដោយ គ.ជ.ប ។

៩.៦.៣.២ ត្រូវតាមដានជាប្រចាំកិច្ចប្រតិបត្តិការ និងនីតិវិធីនៃការបោះឆ្នោត បង្ការក្រែងមានករណីមិនប្រក្រតីក្នុងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

៩.៦.៣.៣ ជួយពិនិត្យ និងតាមដាន ដើម្បីបង្ការ និងទប់ស្កាត់ការបន្លំនាំយកសន្លឹកឆ្នោតផ្លូវការចេញពីការិយាល័យបោះឆ្នោត ។

៩.៦.៣.៤ មិនត្រូវណែនាំ ឬស្តីបន្ទោសអ្វីដល់សមាសភាព គ.ក.ប/គ.ក.រ ។

៩.៦.៣.៥ មិនត្រូវណែនាំ ឬសាកសួរអ្វីចំពោះអ្នកបោះឆ្នោត ។

៩.៦.៣.៦ មិនត្រូវរំខាន ឬជ្រៀតជ្រែកធ្វើឱ្យរាំងស្ទះដល់កិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើយ ។

៩.៦.៣.៧ ត្រូវលើកសំណួរ សំណូមពរផ្សេងៗ ឬ/និងយោបល់ជំទាស់ដោយផ្ទាល់ទៅប្រធាន គ.ក.ប/គ.ក.រ ចំពោះភ្នាក់ងារគណបក្សនយោបាយ ។

៩.៦.៣.៨ ត្រូវបំពេញវត្តមានអ្នកសង្កេតការណ៍ ក្នុងពេលបោះឆ្នោត (ទ.១១២០) ដោយត្រូវបញ្ជាក់ឈ្មោះសាមីអង្គការ ម៉ោងចូល ម៉ោងចេញ និងចុះហត្ថលេខា ។

៩.៦.៣.៩ ត្រូវអញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ចូលតាមទីកន្លែង ដូចបានកំណត់ក្នុងចំណុច ៩.៦.២.៥ ខាងលើ ។

៩.៦.៤ នៅចន្លោះពីម៉ោង ៦:០០ (ប្រាំមួយ) ដល់ម៉ោង ៦:៣០ (ប្រាំមួយកន្លះ) ព្រឹក នៃថ្ងៃបោះឆ្នោត គ.ក.ប ត្រូវត្រួតពិនិត្យ និងបង្ហាញហិបឆ្នោតជូនអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោតតាមនីតិវិធីដូចខាងក្រោម ៖

៩.៦.៤.១ ប្រធានត្រូវពិនិត្យឡើងវិញនូវហិបឆ្នោត ដើម្បីឱ្យប្រាកដថាត្រូវបានដំឡើងត្រឹមត្រូវតាមការណែនាំ ។

៩.៦.៤.២ ប្រធានត្រូវបើកគម្របក្រៅ និងគម្របក្នុងនៃហិបឆ្នោត រួចបង្ហាញហិបឆ្នោតទទេ ចំពោះអ្នកដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោត បន្ទាប់មកត្រូវបិទគម្របក្នុងនៃហិបឆ្នោតទៅវិញ មូលភ្ជិតគម្របសន្ទះបិទប្រឡោះសម្រាប់បោះឆ្នោត ហើយខ្ទាស់គន្លឹះគម្របក្នុងរួចចាក់សោឃ្លុំ និងប្រាប់លេខាធិការឱ្យកត់ត្រាលេខសោឃ្លុំ ក្នុងកំណត់ហេតុនៃការបោះឆ្នោត ។

៩.៦.៤.៣ ប្រធានត្រូវយកក្រដាសលេខកូដការិយាល័យបោះឆ្នោត ០២ (ពីរ) សន្លឹក និងបោះត្រាការិយាល័យបោះឆ្នោត រួចបិទភ្ជាប់ទៅនឹងជញ្ជាំងមុខក្រោយនៃហិបឆ្នោត ហើយបន្ទាប់មក អនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពិនិត្យមើល និងកត់ចំណាំហិបឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ។

៩.៦.៤.៤ លេខាធិការត្រូវកត់ត្រាពេលម៉ោងនៃការពិនិត្យហិបឆ្នោត នៅលើកំណត់ហេតុនៃការបោះឆ្នោត ។

៩.៦.៥ ហិបឆ្នោតដែលបានបិទសម្គាល់លេខកូដការិយាល័យបោះឆ្នោត និងចាក់សោឃ្លុំរួចហើយ ដូចចែងក្នុងចំណុច ៩.៦.៤ ខាងលើ គ.ក.ប ត្រូវធានាដូចខាងក្រោម ៖

៩.៦.៥.១ មិនអនុញ្ញាតឱ្យបើកចំហដាច់ខាត លើកលែងតែក្នុងបំណងរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតនោះ បន្ទាប់ពីការបោះឆ្នោតបានបញ្ចប់។

៩.៦.៥.២ មិនអនុញ្ញាតឱ្យយកចេញពីការិយាល័យបោះឆ្នោត លើកលែងតែ គ.ជ.ប សម្រេចឱ្យរាប់សន្លឹកឆ្នោតនៅកន្លែងផ្សេង ក្នុងករណីប្រធានសក្តិឬអសន្តិសុខ ។

៩.៦.៦ ប្រសិនបើ សម្ភារ ឯកសារបោះឆ្នោតសម្រាប់ការិយាល័យបោះឆ្នោត ត្រូវបានប្រគល់ ទទួលនៅក្រោយម៉ោង ៦:៣០ (ប្រាំមួយកន្លះ) ប៉ុន្តែមិនហួសពីម៉ោង ៧:០០ (ប្រាំពីរ) ព្រឹក ប្រធាន គ.ក.ប ត្រូវព្យួរការអនុវត្តនីតិវិធីដូចចែងក្រោមចំណុច ៩.៦.៧ នៅការិយាល័យបោះឆ្នោតនោះជាបណ្តោះអាសន្នសិន រហូតទាល់តែនីតិវិធីដូចចែងក្រោមចំណុច ៩.៦.៤ ខាងលើ ត្រូវបានបំពេញចប់សព្វគ្រប់ ។ ក្នុងករណីនេះ លេខាធិការត្រូវកត់ត្រាអំពីពេល ម៉ោងនៃការអនុវត្តនីតិវិធីបោះឆ្នោត នីមួយៗទៅក្នុងកំណត់ហេតុនៃការបោះឆ្នោតឱ្យបានច្បាស់លាស់ ។

៩.៦.៧ នៅចន្លោះពីម៉ោង ៦:៣០ (ប្រាំមួយកន្លះ) ដល់ម៉ោង ៧:០០ (ប្រាំពីរ) ព្រឹក នៃថ្ងៃបោះឆ្នោត គ.ក.ប ត្រូវត្រួតពិនិត្យ និងរាប់ចំនួនសន្លឹកឆ្នោត ដែលទទួលជាក់ស្តែង ព្រមទាំងត្រួតពិនិត្យ និងបង្ហាញត្រាសម្ងាត់ផ្លូវការសម្រាប់ការិយាល័យបោះឆ្នោតនោះ ចំពោះភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន ។

៩.៦.៧.១ អនុប្រធានត្រូវត្រួតពិនិត្យមើលកញ្ចប់សន្លឹកឆ្នោត ដើម្បីឱ្យប្រាកដថាសន្លឹកឆ្នោតនេះ ជាសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នោះប្រាកដមែន ។ ក្នុងករណី ពិនិត្យឃើញថាសន្លឹកឆ្នោតនេះមិនមែនជាសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធទេ គ.ក.ប ត្រូវរាយការណ៍ជាបន្ទាន់តាមរយៈ គឃ.សប និង គធ.ខប ជូន គ.ជ.ប ដើម្បីមានវិធានការដោះស្រាយ ។

៩.៦.៧.២ បន្ទាប់មក អនុប្រធានត្រូវបើកកញ្ចប់សន្លឹកឆ្នោត រួចរាប់សន្លឹកឆ្នោតដែលជាធម្មតាមានចំនួនលើសចំនួនអ្នកបោះឆ្នោត ដែលមានក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតនោះ ក្នុងចន្លោះពី ៥០ (ហាសិប) ដល់ ៩៩ (កៅសិបប្រាំបួន) សន្លឹក ។

៩.៦.៧.៣ លេខាធិការត្រូវកត់ត្រាចំនួនសន្លឹកឆ្នោត ដែលបានរាប់ឃើញជាក់ស្តែង ព្រមទាំងលេខរៀងសន្លឹកឆ្នោតដំបូងនៃក្បាលទី១ និងលេខរៀងសន្លឹកឆ្នោតចុងក្រោយនៃក្បាលចុងក្រោយ ទៅក្នុងកំណត់ហេតុនៃការបោះឆ្នោត ។ ទោះបីសន្លឹកឆ្នោតរាប់ឃើញជាក់ស្តែងមានចំនួនលើស ឬខ្វះ ធៀបនឹងចំនួនសន្លឹកឆ្នោតដែលត្រូវប្រគល់ឱ្យក្តី ក៏លេខាធិការត្រូវកត់ត្រាចំនួនលើស ឬខ្វះនោះ ទៅក្នុងកំណត់ហេតុនៃការបោះឆ្នោតដែរ ។

៩.៦.៧.៤ លេខាធិការត្រូវពិនិត្យចំនួនអ្នកបោះឆ្នោត ដែលមាននៅក្នុងបញ្ជីបោះឆ្នោត និងកត់ត្រាចំនួននេះទៅក្នុងកំណត់ហេតុនៃការបោះឆ្នោត ។

៩.៦.៧.៥ ប្រធានត្រូវបើកស្រោមសំបុត្រ ដែលមានត្រាសម្ងាត់សម្រាប់បោះនៅលើខ្នងសន្លឹកឆ្នោត រួចដកយកត្រានោះមកបោះសាកល្បងនៅលើក្រដាសធម្មតាពណ៌ស និងលើកបង្ហាញអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោតទាំងអស់ឱ្យបានឃើញច្បាស់ និងចំណាំបានរូបសញ្ញានៃត្រានោះ ។

៩.៦.៨ ប្រធាន គ.ក.ប ត្រូវប្រកាសបើកការបោះឆ្នោតនៅការិយាល័យបោះឆ្នោតរបស់ខ្លួន នៅម៉ោង ៧:០០ (ប្រាំពីរ) ព្រឹក នៃថ្ងៃបោះឆ្នោត និងអញ្ជើញសមាសភាព គ.ក.ប ឱ្យបោះឆ្នោតមុនគេបង្អស់ រួចបន្ទាប់មកភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកយកព័ត៌មាន ប្រសិនបើអ្នកទាំងនេះ មានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ។ ផ្អែកតាមករណីដូចចែងក្នុង ចំណុច ៩.៦.៦ ខាងលើ ប្រសិនបើប្រធាន គ.ក.ប មិនអាចប្រកាសបើកការិយាល័យបោះឆ្នោតនៅម៉ោង ៧:០០ (ប្រាំពីរ) ព្រឹកបាន គាត់អាចប្រកាសបើកការិយាល័យបោះឆ្នោតនៅក្រោយម៉ោង ម៉ោង៧:០០ (ប្រាំពីរ) ព្រឹក ប៉ុន្តែមិនត្រូវឱ្យហួសពីម៉ោង៨:០០ (ម៉ោងប្រាំបី) ព្រឹកឡើយ។

៩.៦.៩ បន្ទាប់ពីបានបោះឆ្នោតរួចហើយ សមាជិកទី២ត្រូវបន្តចាត់ចែងសណ្តាប់ធ្នាប់អ្នកបោះឆ្នោតនៅបរិវេណខាងក្នុង ដោយជួយរកឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ប្រាប់លេខរៀងឈ្មោះរបស់គាត់ ចេញក្រដាសលេខរៀងតាមលំដាប់មុនក្រោយ និងណែនាំអ្នកបោះឆ្នោតឱ្យឈរបន្តកន្ទុយគ្នាជាជួរ ។

៩.៦.១០ បន្ទាប់ពីប្រធាន គ.ក.ប ប្រកាសបើកការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ សមាជិកទី ៣ ដែលប្រចាំការនៅត្រង់មាត់ទ្វារ ត្រូវជម្រាបអ្នកបោះឆ្នោត ដែលកំពុងឈរជាជួរបន្តកន្ទុយគ្នាតម្រង់ទៅកាន់មាត់ទ្វារចូលការិយាល័យបោះឆ្នោត អំពីអាទិភាពក្នុងការចូលបោះឆ្នោតតាមលំដាប់លំដោយគឺ ព្រះសង្ឃ ជនចាស់ជរា ស្ត្រីមានផ្ទៃពោះ ស្ត្រីមានកូនតូច អ្នកមានជំងឺ ជនពិការដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង និងអ្នកជំនួយអមដំណើរជនពិការនោះ ព្រមទាំងអ្នកឈរក្នុងជួរខាងមុខគេ។ សមាជិកទី៣ អាចសួររំលឹកអ្នកបោះឆ្នោតថា បានស្នើឱ្យសមាជិកទី ២ ជួយរកឈ្មោះ និងឃើញឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនេះហើយឬនៅ ។ សមាជិកទី៣ ត្រូវអនុញ្ញាតឱ្យអ្នកបោះឆ្នោតមានវត្តមាន ក្នុងការិយាល័យបោះឆ្នោតតែចំនួន ០៤(បួន)នាក់ ក្នុងពេលតែមួយ ដោយត្រូវយកចិត្តទុកដាក់ ដូចខាងក្រោម ៖

៩.៦.១០.១ ត្រូវពិនិត្យមើលអ្នកបោះឆ្នោតមាន អ.ខ ឬ ឯ.អ សម្រាប់បោះឆ្នោត ឬទេ ?

៩.៦.១០.២ ត្រូវពិនិត្យមើលម្រាមដៃអ្នកបោះឆ្នោត ដែលពិតជាពុំមានស្នាមទឹកខ្មៅលុបមិនជ្រះមែន ។ ករណីឃើញមានស្នាមប្រឡាក់ទឹកខ្មៅលុបមិនជ្រះ ត្រូវនាំគាត់ទៅជួបប្រធាន គ.ក.ប ។

៩.៦.១០.៣ ត្រូវជម្រាបអ្នកបោះឆ្នោតដែលចូលក្នុងការិយាល័យបោះឆ្នោត ឱ្យដើរតម្រង់ទៅតុលេខាធិការ និងអនុប្រធាន និងឱ្យបង្ហាញ អ.ខ ឬ ឯ.អ ទៅលេខាធិការ ។

៩.៦.១១ នៅពេលអ្នកបោះឆ្នោតចូលមកដល់ លេខាធិការ ត្រូវសុំឱ្យអ្នកបោះឆ្នោតបង្ហាញ អ.ខ ឬ ឯ.អ របស់ខ្លួន ។ ពេលនោះ លេខាធិការត្រូវ ៖

៩.៦.១១.១ ត្រួតពិនិត្យម្រាមដៃរបស់អ្នកបោះឆ្នោត ដើម្បីបញ្ជាក់ឱ្យប្រាកដថា គ្មានស្នាមទឹកខ្មៅលុបមិនជ្រះជាប់នៅលើម្រាមដៃគាត់ទេ ។

៩.៦.១១.២ ពិនិត្យមើលលេខរៀងនៅលើបណ្ណព័ត៌មាន ( ប្រសិនបើមាន ) ដើម្បីរកឈ្មោះអ្នកបោះឆ្នោត រួចប្រគល់បណ្ណព័ត៌មានជូនអ្នកបោះឆ្នោតវិញ ។ បន្ទាប់មកស្វែបញ្ជាក់ឈ្មោះ ពិនិត្យផ្ទៀងផ្ទាត់ អ.ខ ឬ ឯ.អ របស់គាត់ជាមួយនឹងរូបពិត រួចពិនិត្យផ្ទៀងផ្ទាត់ជាមួយនឹងរូបថត ឈ្មោះ និងទិន្នន័យពាក់ព័ន្ធនៅក្នុងបញ្ជីបោះឆ្នោត ។

៩.៦.១១.៣ ដាក់បន្ទាត់តម្រង់តាមបណ្តោយជួរឈ្មោះរបស់គាត់ និងគូសសញ្ញាធិច បញ្ជាក់ការបានមកបោះឆ្នោតរបស់អ្នកបោះឆ្នោត ក្នុងកូនប្រអប់ទំនេរ នៅប៉ែកខាងដើម ទន្ទឹមនឹងឈ្មោះអ្នកបោះឆ្នោតនោះ រួចហុច អ.ខ ឬ ឯ.អ របស់គាត់បន្តទៅឱ្យអនុប្រធាន ប្រសិនបើឈ្មោះ និងទិន្នន័យក្នុង អ.ខ ឬ ឯ.អ របស់អ្នកបោះឆ្នោត ដូចគ្នានឹងឈ្មោះ និងទិន្នន័យក្នុងបញ្ជីបោះឆ្នោត ។

៩.៦.១១.៤ ប្រាប់អ្នកបោះឆ្នោតឱ្យទៅទទួលយកសន្លឹកឆ្នោតពីអនុប្រធាន ។

៩.៦.១២ ប្រសិនបើ ក្នុងពេលអនុវត្តក្រោមចំណុច ៩.៦.១១ លេខាធិការបានរកឃើញថាអ្នកបោះឆ្នោតមានស្នាមប្រឡាក់ទឹកខ្មៅលុបមិនជ្រះជាប់នៅនឹងម្រាមដៃ ឬរូបថតមិនដូចគ្នា ឬឈ្មោះ និងទិន្នន័យមិនដូចគ្នា ត្រូវជូនអ្នកបោះឆ្នោតនោះទៅជួបប្រធាន គ.ក.ប ដើម្បីរាយការណ៍អំពីករណីនេះ ។

៩.៦.១២.១ ប្រធានត្រូវអញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ឱ្យមកធ្វើការកត់សម្គាល់អំពីបញ្ហានេះ ហើយត្រូវឱ្យអ្នកបោះឆ្នោតរូបនេះពន្យល់អំពីស្នាមទឹកខ្មៅលុបមិនជ្រះ ដែលមានជាប់នឹងម្រាមដៃរបស់គាត់ ឬរូបថតមិនដូចគ្នា ឬឈ្មោះ និងទិន្នន័យមិនដូចគ្នា ។

៩.៦.១២.២ ប្រសិនបើ អ្នកបោះឆ្នោតនោះមិនអាចផ្តល់ការពន្យល់របស់ខ្លួនបាន សមហេតុផលអំពីបញ្ហាទឹកខ្មៅ ឬរូបថតមិនដូចគ្នា ឬឈ្មោះ និងទិន្នន័យ មិនដូចគ្នានេះទេ នោះគាត់នឹងត្រូវបានសន្និដ្ឋានថា មានបំណងបោះឆ្នោត លើសពីមួយដង ឬមានចេតនាទុច្ចរិតក្នុងបោះឆ្នោត ដែលត្រូវមាន ទោសតាមច្បាប់ ។

៩.៦.១២.៣ ប្រធាន ត្រូវដកហូត អ.ខ ឬ ឯ.អ របស់គាត់ជាបណ្តោះអាសន្ន ហើយ បញ្ជូនទៅ គឃ.សប ដើម្បីចាត់វិធានការបន្ត ។

៩.៦.១២.៤ លេខាធិការត្រូវកត់ត្រាទុកអំពីហេតុការណ៍នេះ នៅក្នុងកំណត់ហេតុ នៃការបោះឆ្នោត និងត្រូវស្រង់ឈ្មោះ និងទិន្នន័យពី អ.ខ ឬ ឯ.អ របស់ជននោះ សម្រាប់ជាការតាមដានបន្ថែមទៀត ។

៩.៦.១២.៥ ប្រសិនបើអ្នកបោះឆ្នោតនោះ មិនយល់ព្រមតាមការអនុវត្តនីតិវិធីខាងលើ ប្រធាន គ.ក.ប ឬ គឃ.សប ត្រូវស្នើសុំអាជ្ញាធរមានសមត្ថកិច្ចឱ្យ ឃាត់ខ្លួនជននោះ រហូតដល់ការបោះឆ្នោតត្រូវបានបញ្ចប់ ។

៩.៦.១៣ ប្រសិនបើ ក្នុងពេលអនុវត្តចំណុច ៩.៦.១១.២ លេខាធិការមិនឃើញមានឈ្មោះ អ្នកបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោតទេ ត្រូវជូនអ្នកបោះឆ្នោតនោះ ទៅជួបប្រធាន គ.ក.ប និងរាយការណ៍អំពីករណីនេះជូនប្រធាន ។

៩.៦.១៣.១ ប្រធានត្រូវប្រាប់អ្នកបោះឆ្នោតនោះថា គាត់មិនអាចបោះឆ្នោតនៅ ការិយាល័យបោះឆ្នោតនេះបានទេ ព្រោះទោះបីគាត់មាន អ.ខ ឬ ឯ.អ ក្តី ប៉ុន្តែគាត់គ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ។

៩.៦.១៣.២ ប្រសិនបើជាករណីច្រឡំការិយាល័យបោះឆ្នោត ប្រធានអាចស្វែងរក បណ្តាព័ត៌មានអ្នកបោះឆ្នោតរបស់គាត់ដើម្បីផ្ទៀងផ្ទាត់ និងត្រូវណែនាំ គាត់អំពីទីតាំងការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ដែល ឈ្មោះរបស់គាត់មានក្នុងបញ្ជីបោះឆ្នោត ។

៩.៦.១៣.៣ ប្រធានត្រូវប្រាប់គាត់ឱ្យចេញពីការិយាល័យបោះឆ្នោត ។

៩.៦.១៤ បន្ទាប់ពីអនុវត្តនីតិវិធី ដូចចែងក្រោមចំណុច ៩.៦.១១ រួច អនុប្រធានត្រូវហែក សន្លឹកឆ្នោត ០១ (មួយ) សន្លឹកចេញពីគល់បញ្ជី រួចបោះត្រាសម្ងាត់នៅលើផ្នែក ខាងខ្នង និងបត់ជា ០៤ (បួន) ផ្នត់ តាមការកំណត់របស់ គ.ជ.ប ហើយប្រគល់ជូន

អ្នកបោះឆ្នោត រួមជាមួយ អ.ខ ឬ ឯ.អ របស់គាត់ផង ។ អនុប្រធានមិនត្រូវប្រគល់សន្លឹកឆ្នោត និងមិនត្រូវអនុញ្ញាតឱ្យអ្នកបោះឆ្នោតបន្ទាប់ ចូលក្នុងបន្ទប់សម្ងាត់ទេ ប្រសិនបើអ្នកបោះឆ្នោតមុនមិនទាន់ចេញផុតពីបន្ទប់សម្ងាត់ សម្រាប់គូសសន្លឹកឆ្នោតនៅឡើយ ។ នៅពេលប្រគល់សន្លឹកឆ្នោតជូនអ្នកបោះឆ្នោតរួចហើយ អនុប្រធានត្រូវណែនាំជាសង្ខេបចំពោះអ្នកបោះឆ្នោតដូចខាងក្រោម ៖

៩.៦.១៤.១ នេះគឺជាសន្លឹកឆ្នោត ។

៩.៦.១៤.២ អ្នកត្រូវដើរទៅកាន់បន្ទប់សម្ងាត់ ប្រើប៊ិកដែលមាននៅទីនោះស្រាប់ ឬប៊ិកផ្ទាល់ខ្លួន (លើកលែងតែខ្មៅដៃ) អ្នកត្រូវគូសសញ្ញាគាំទ្រនៅក្នុងប្រឡោះប្ួនជ្រុងទ្រវែង នៃគណបក្សនយោបាយដែលអ្នកពេញចិត្ត ។ អ្នកត្រូវគិតពិចារណា ឱ្យបានហ្មត់ចត់មុននឹងគូសសញ្ញា ដើម្បីបង្ការការខូចសន្លឹកឆ្នោត ដោយសារការផ្លាស់ប្តូរចិត្ត បន្ទាប់ពីបានគូសសញ្ញារួច ។

៩.៦.១៤.៣ មុននឹងចេញពីបន្ទប់សម្ងាត់ អ្នកត្រូវបត់សន្លឹកឆ្នោតតាមផ្នត់ដើម ដើម្បីឱ្យសញ្ញាដែលអ្នកបានគូសស្ថិតនៅក្នុងផ្នត់មិនអាចមើលឃើញ និងឱ្យរូបសញ្ញានៃត្រាសម្ងាត់ស្ថិតនៅខាងក្រៅ ។

៩.៦.១៥ ក្រោយពេលទទួលបានសន្លឹកឆ្នោត អ្នកបោះឆ្នោតមិនត្រូវសួរអ្នកណាម្នាក់ក្នុងការិយាល័យបោះឆ្នោត ឱ្យបង្ហាញពីគណបក្សនយោបាយជាក់លាក់ណាមួយ នៅលើសន្លឹកឆ្នោត ឬ/និងមិនត្រូវធ្វើសកម្មភាពណាមួយ ដែលរំលោភទៅលើការសម្ងាត់នៃការបោះឆ្នោតឡើយ ។

៩.៦.១៥.១ អ្នកបោះឆ្នោតមិនត្រូវសួរនាំ ឬប្រាប់អ្នកណាម្នាក់ក្នុងការិយាល័យបោះឆ្នោត ឱ្យដឹងអំពីគណបក្សនយោបាយជាក់លាក់ណាមួយដែលគាត់ពេញចិត្ត ឬមិនពេញចិត្តឡើយ ។

៩.៦.១៥.២ អ្នកបោះឆ្នោតទូទៅ ទោះបីមិនចេះអក្សរក៏ដោយ ក៏មិនអាចស្នើសុំជំនួយពីជនណាម្នាក់ ដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោត ឱ្យជួយគាត់ក្នុងការបោះឆ្នោតឡើយ លើកលែងតែអ្នកបោះឆ្នោតជាជនពិការ ដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង ដូចចែងក្នុងចំណុច ៩.៦.១៨ ខាងក្រោម ។

៩.៦.១៥.៣ ភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ ដែលនៅក្នុងការិយាល័យបោះឆ្នោត មិនត្រូវបានអនុញ្ញាតឱ្យជួយអ្នកបោះឆ្នោតក្នុងការបោះឆ្នោតទេ ទោះបីអ្នកបោះឆ្នោតនោះស្នើសុំឱ្យជួយក៏ដោយ ។

៩.៦.១៥.៤ ហាមអ្នកបោះឆ្នោត និងអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោត ប្រើទូរស័ព្ទដៃ ឬ/និងម៉ាស៊ីនថត ឬ/និងឧបករណ៍ផ្សេងទៀតដែលអាចថតរូបបាន និងហាមធ្វើសកម្មភាពរំលោភលើការសម្ងាត់នៃការបោះឆ្នោតក្នុងការិយាល័យបោះឆ្នោត ។ អ្នកសារព័ត៌មាន ដែលទទួលស្គាល់ដោយ គ.ជ.ប និងបានការអនុញ្ញាតពីប្រធាន គ.ក.ប អាចថតយកសកម្មភាពនៅការិយាល័យបោះឆ្នោត ប៉ុន្តែមិនត្រូវរំលោភលើការសម្ងាត់នៃការបោះឆ្នោត ។

៩.៦.១៦ បន្ទាប់ពីទទួលបានសន្លឹកឆ្នោត និងអនុវត្តតាមការណែនាំរបស់អនុប្រធាន ដូចចែងក្នុងចំណុច ៩.៦.១៤.២ និង ៩.៦.១៤.៣ ខាងលើរួច អ្នកបោះឆ្នោតត្រូវចេញពីបន្ទប់សម្ងាត់ ហើយដើរតម្រង់ទៅតុដាក់ហិបឆ្នោត ។

៩.៦.១៦.១ អ្នកបោះឆ្នោតត្រូវបង្ហាញសន្លឹកឆ្នោតរបស់ខ្លួន ដែលបានបត់រួចនោះដោយដាក់បែរផ្នែកខាងខ្នង ដែលមានបោះត្រាសម្ងាត់ទៅរកសមាជិកទី១ ហើយស៊កវាដោយខ្លួនឯង តាមប្រឡោះតូចចូលទៅក្នុងហិបឆ្នោត (លើកលែងតែអ្នកបោះឆ្នោតជាជនពិការ ដែលមិនអាចស៊កដោយខ្លួនឯងបាន) ។

៩.៦.១៦.២ ស្របពេលដែលអ្នកបោះឆ្នោតបង្ហាញសន្លឹកឆ្នោត ដែលបត់រួចបម្រុងនឹងស៊កទៅក្នុងហិបឆ្នោត សមាជិកទី ១ ត្រូវពិនិត្យឱ្យប្រាកដថាពិតជាសន្លឹកឆ្នោតផ្លូវការតែមួយសន្លឹក ដែលមានបោះត្រាសម្ងាត់ជាផ្លូវការសម្រាប់ការិយាល័យនោះ ។

៩.៦.១៦.៣ បន្ទាប់មក អ្នកបោះឆ្នោតត្រូវយល់ព្រមឱ្យសមាជិកទី ១ ជ្រលក់ឱ្យលិចដល់គល់ក្រចកនៃម្រាមចង្អុលដៃស្ដាំ ឬម្រាមផ្សេងទៀត ប្រសិនបើម្រាមចង្អុលដៃស្ដាំពិការ ចូលទៅក្នុងដបទឹកខ្មៅលុបមិនជ្រះ ដូចដែលបានកំណត់ក្រោមចំណុច ៩.៦.១៧ ខាងក្រោម ។

៩.៦.១៦.៤ ប្រសិនបើ សមាជិកទី១ ពិនិត្យឃើញថា អ្នកបោះឆ្នោតណាម្នាក់បានស៊កសន្លឹកឆ្នោតក្លែងក្លាយ ឬវត្ថុផ្សេងទៀតចូលទៅក្នុងហិបឆ្នោត ត្រូវរាយការណ៍ជាបន្ទាន់ទៅប្រធាន គ.ក.ប ។ ក្នុងករណីនេះ ប្រធាន គ.ក.ប ត្រូវប្រកាសប្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នក-សង្កេតការណ៍ ដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោត មុននឹងចាត់វិធានការឆែកឆេរ រកសន្លឹកឆ្នោតផ្លូវការ ។

៩.៦.១៦.៥ ប្រសិនបើមានអ្នកបោះឆ្នោតណាម្នាក់ ដែលត្រូវបានសមាជិកទី ១ ចាប់ភស្តុតាងបានថា មានបំណងស៊កសន្លឹកឆ្នោតក្លែងក្លាយ ឬ/និងវត្ថុផ្សេងទៀត ឬ/និងសន្លឹកឆ្នោតលើសពី ០១ (មួយ) សន្លឹក ទៅក្នុងហិបឆ្នោត ឬ/និងលាក់ទុកសន្លឹកឆ្នោតផ្លូវការ ដើម្បីនាំចេញទៅក្រៅការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតនោះត្រូវតែមានទោសដោយផ្អែកតាម ច.ប.ឃ.ស ។

៩.៦.១៦.៦ ប្រធាន គ.ក.ប ត្រូវឃាត់អ្នកបោះឆ្នោត ដូចបញ្ជាក់ក្នុងចំណុច ៩.៦.១៦.៥ ខាងលើ មិនឱ្យបោះឆ្នោត រួចដកហូតសន្លឹកឆ្នោតមិនត្រឹមត្រូវទាំងនោះ និងឆែកឆេរកសន្លឹកឆ្នោតផ្លូវការ (ប្រសិនបើមាន) ដាក់ទៅក្នុងស្រោមសំបុត្រមានកាខ្វងថា " សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត " បន្ទាប់មកត្រូវដកហូត អ.ខ ឬ ឯ.អ របស់ជននោះជាបណ្ដោះអាសន្ន ព្រមទាំងចាត់ចែងឱ្យធ្វើកំណត់ហេតុ និងបំពេញទម្រង់បែបបទប្ដឹង ចោទប្រកាន់ជនប្រព្រឹត្តអំពើល្មើសទៅ គឃ.សប ។

៩.៦.១៦.៧ ប្រសិនបើជនដែលបានប្រព្រឹត្តអំពើល្មើស ជាបេក្ខជនឈរឈ្មោះបោះឆ្នោត ហើយបើមានភស្តុតាងគ្រប់គ្រាន់នោះ គឃ.សប ត្រូវបន្តប្ដឹងទៅ គជ.ខប និង គ.ជ.ប ដើម្បីចាត់វិធានការតាមផ្លូវច្បាប់ ។

៩.៦.១៧ ទឹកខ្មៅលុបមិនជ្រះដែលអាចមើលឃើញច្បាស់ ត្រូវបានដាក់បញ្ញត្តិឱ្យប្រើ ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ សម្រាប់បង្ការការបោះឆ្នោត លើសពី ០១ (មួយ) ដង ។

៩.៦.១៧.១ ក្នុងការិយាល័យបោះឆ្នោតនីមួយៗ ត្រូវបានផ្គត់ផ្គង់ទឹកខ្មៅលុបមិនជ្រះចំនួន ០២ (ពីរ) ដប ។

៩.៦.១៧.២ ដបទឹកខ្មៅលុបមិនជ្រះ ០១ (មួយ) ដប ត្រូវបានបើកគម្រប ប្រើនៅពេលបើកការបោះឆ្នោតនៅថ្ងៃបោះឆ្នោត និងបម្រុងទុក ០១ (មួយ) ដបសម្រាប់ប្រើនៅពេលអស់ទឹកខ្មៅដបទីមួយ ។

៩.៦.១៧.៣ បន្ទាប់ពីអ្នកបោះឆ្នោតបានស៊កសន្លឹកឆ្នោតរបស់ខ្លួន ទៅក្នុងហិបឆ្នោត និងនៅមុនពេលគាត់ដើរចេញពីការិយាល័យបោះឆ្នោត គាត់ត្រូវយល់ព្រមឱ្យសមាជិកទី ១ ជ្រលក់ម្រាមចង្អុលដៃស្ដាំរបស់គាត់ឱ្យលិចគល់ក្រចកទៅក្នុងដបទឹកខ្មៅលុបមិនជ្រះ និងរង់ចាំរហូតដល់ស្ងួតបន្តិចប្រមាណ ៣០វិនាទី ទើបចេញពីការិយាល័យបោះឆ្នោត ។

៩.៦.១៧.៤ ក្នុងករណី ម្រាមចង្អុលដៃស្តាំពិការ អ្នកបោះឆ្នោតត្រូវប្រើម្រាមដៃផ្សេងណាមួយតាមលំដាប់លំដោយដូចតទៅ ៖ ម្រាមចង្អុលខ្មោចស្តាំ ឬនាងដៃស្តាំ ឬកូនដៃស្តាំ ឬមេដៃស្តាំ ឬមេដៃឆ្វេង ឬ ចង្អុលដៃឆ្វេង ឬម្រាមចង្អុលខ្មោចឆ្វេង ឬនាងដៃឆ្វេង ឬកូនដៃឆ្វេង ។ ប្រសិនបើគាត់មិនអាចធ្វើបានតាមការកំណត់ខាងលើរាល់ការជ្រលក់ ឬលាបត្រង់ផ្នែកណាមួយនៃអវយវៈរបស់គាត់ត្រូវទទួលយកជាបានការ ។

៩.៦.១៧.៥ រៀងរាល់ ៣០ (សាមសិប) នាទីម្តង ដបទឹកខ្មៅលុបមិនជ្រះ ត្រូវតែបានបិទគម្របយ៉ាងជិតហើយក្រឡុក ។

៩.៦.១៧.៦ ប្រសិនបើគ្មានអ្នកបោះឆ្នោតមួយរយៈពេលយូរគួរសម សមាជិកទី ១ ត្រូវបិទគម្របដបទឹកខ្មៅ ដើម្បីការពារកុំឱ្យវាហួត ។

៩.៦.១៨ គ្មានជនណាម្នាក់ចូលទៅជ្រៀតជ្រែកនៅក្នុងការិយាល័យបោះឆ្នោត ឬជួយអ្នកបោះឆ្នោតក្នុងការបោះឆ្នោតបានឡើយ លើកលែងតែអ្នកបោះឆ្នោតនោះជាជនពិការ ដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង ហើយបានស្នើសុំអ្នកជំនួយជានីតិជនម្នាក់ មកជាមួយ ឬស្នើសុំជំនួយពី ប្រធាន គ.ក.ប ដូចចែងក្នុងមាត្រា ១១៦ នៃ ច.ប.ឃ.ស ដោយត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម ៖

៩.៦.១៨.១ បន្ទាប់ពីបានអនុញ្ញាតឱ្យចូលការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតជាជនពិការមិនអាចបោះឆ្នោតដោយខ្លួនឯងបាន និងអ្នកជំនួយជានីតិជនម្នាក់ ដែលអមដំណើរជាមួយដើម្បីជួយគាត់ក្នុងការបោះឆ្នោត ត្រូវអនុវត្តជាបន្តបន្ទាប់តាមចំណុច ៩.៦.១១ ៩.៦.១៤ និង ៩.៦.១៦ ខាងលើ ។

៩.៦.១៨.២ បន្ទាប់ពីបានចូលក្នុងការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតជាជនពិការមិនអាចបោះឆ្នោតបានដោយខ្លួនឯង ដែលមានបំណងស្នើសុំជំនួយពីប្រធាន គ.ក.ប ត្រូវទៅជួបប្រធានដោយផ្ទាល់ ។ បន្ទាប់មកប្រធានត្រូវអមដំណើរអ្នកបោះឆ្នោតជាជនពិការនោះ អនុវត្តជាបន្តបន្ទាប់តាមចំណុច ៩.៦.១១ ៩.៦.១៤ និង ៩.៦.១៦ ខាងលើ ។ ក្នុងករណីនេះប្រធានអាចចាត់សមាជិក គ.ក.ប ណាម្នាក់ឱ្យជួយ ក៏បានប៉ុន្តែត្រូវមានការយល់ព្រមពីសាមីខ្លួន ។

៩.៦.១៨.៣ អ្នកបោះឆ្នោតជាជនពិការ ដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង ត្រូវសួរនាំ ឬប្រាប់អំពីគណបក្សនយោបាយដែលខ្លួនពេញចិត្តទៅប្រធាន គ.ក.ប ឬអ្នកជំនួយ ដែលខ្លួនជ្រើសរើសតែនៅក្នុងបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោតប៉ុណ្ណោះ ។

៩.៦.១៨.៤ នៅក្នុងបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត ប្រធាន ឬសមាជិក គ.ក.ប ឬអ្នកជំនួយដែលជួយអ្នកបោះឆ្នោត ជាជនពិការក្នុងការបោះឆ្នោត ត្រូវសួរអ្នកបោះឆ្នោតជាជនពិការនោះថា តើគាត់បោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ដោយសួរតិចៗធ្វើយ៉ាងណាកុំឱ្យមនុស្សដែលនៅក្នុងការិយាល័យបោះឆ្នោតឮឱ្យសោះ ។ បន្ទាប់មកប្រធាន ឬសមាជិក គ.ក.ប ឬអ្នកជំនួយត្រូវគូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយនៅលើសន្លឹកឆ្នោត ដែលឆ្លើយតបនឹងការជ្រើសរើសរបស់អ្នកបោះឆ្នោតពិការ ហើយបត់សន្លឹកឆ្នោតនោះ តាមផ្នត់ដើម ដើម្បីឱ្យសញ្ញាដែលបានគូសស្ថិត នៅក្នុងផ្នត់រួចត្រូវនាំអ្នកបោះឆ្នោតពិការទៅកាន់ហិបឆ្នោត និងជួយស៊កសន្លឹកឆ្នោតរបស់គាត់តាមប្រឡោះតូចចូលទៅក្នុងហិបឆ្នោត ។

៩.៦.១៨.៥ ប្រធាន ឬសមាជិក គ.ក.ប ឬអ្នកជំនួយដែលបានជួយអ្នកបោះឆ្នោតជាជនពិការ ដូចលក្ខខណ្ឌក្រោមចំណុច ៩.៦.១៨ ត្រូវរក្សាការសម្ងាត់នៃការបោះឆ្នោតរបស់គាត់ ។

៩.៦.១៩ ចំពោះអ្នកបោះឆ្នោតដែលជាជនពិការភ្នែកទាំងសងខាង ហើយមានបំណងចង់បោះឆ្នោតដោយខ្លួនឯង ប្រធាន គ.ក.ប ត្រូវណែនាំអ្នកបោះឆ្នោតនោះឱ្យប្រើក្របក្រដាសពិសេស ដែលជាសម្ភារជំនួយដល់ការបោះឆ្នោត ។

៩.៦.១៩.១ ប្រធាន គ.ក.ប ត្រូវណែនាំអ្នកបោះឆ្នោតដែលជាជនពិការនោះទៅជួបលេខាធិការ ដើម្បីអនុវត្តនីតិវិធីដូចចែងក្រោមចំណុច ៩.៦.១១ ខាងលើ ។ នៅពេលអនុវត្តចំណុច ៩.៦.១១ រួចរាល់ លេខាធិការត្រូវហុចឯកសារពាក់ព័ន្ធជូនអនុប្រធាន គ.ក.ប ។

៩.៦.១៩.២ អនុប្រធាន គ.ក.ប ត្រូវហែកសន្លឹកឆ្នោត ០១(មួយ)សន្លឹក ចេញពីគល់បញ្ជី រួចបោះត្រាសម្ងាត់នៅលើផ្នែកខាងខ្នង បត់ជា ០៤ (បួន)ផ្នត់តាមការកំណត់ និងត្រូវណែនាំអ្នកពិការឱ្យស្ទាបសន្លឹកឆ្នោត និង

ស្នាមបត់ រួចលាសន្លឹកឆ្នោតឱ្យស្មើឡើងវិញ និងដាក់នៅក្នុងក្រប ក្រដាសពិសេស ដោយឱ្យផ្នែកខាងមុខនៃសន្លឹកឆ្នោតលេចចេញប្រអប់ សម្រាប់គូសសញ្ញាគាំទ្រគណបក្សតាមប្រហោងសម្រាប់គូស និងប្រើ ឃ្នាបគាបសន្លឹកឆ្នោតនោះភ្ជាប់នឹងក្របក្រដាសពិសេស ដើម្បីបង្ការ កុំឱ្យប្រអប់លេខរៀង សម្រាប់គូសសញ្ញាគាំទ្រគណបក្សនយោបាយ ឯាក ឬល្អៀងចេញពីប្រហោងនៃក្របក្រដាសពិសេស។

៩.៦.១៩.៣ អនុប្រធាន គ.ក.ប ត្រូវប្រគល់ក្របក្រដាសពិសេស ដែលមានដាក់ សន្លឹកឆ្នោតខាងក្នុង ជូនទៅអ្នកបោះឆ្នោតដែលជាជនពិការ និងកាន់ ម្រាមដៃណាមួយរបស់គាត់ឱ្យមកប៉ះ និងស្ទាបប្រហោងរាងបួនជ្រុង ទ្រវែងដែលចោះលើក្របក្រដាសពិសេសពីលើចុះក្រោម និងជម្រាប គាត់ថា ៖

- អ្នកអាចស្ទាប និងរាប់ប្រហោងរាងបួនជ្រុងទ្រវែង ដែលកំណត់ លេខរៀង និងចំនួនគណបក្សនយោបាយទាំងអស់ នៅលើ សន្លឹកឆ្នោត ។ ប្រហោងរាងបួនជ្រុងទ្រវែង គឺជាប្រអប់សម្រាប់ គូសសញ្ញាគាំទ្រគណបក្សនយោបាយ ដែលមានបញ្ជីបេក្ខជន ឈរឈ្មោះក្នុងឃុំ សង្កាត់នេះ។
- អ្នកត្រូវចងចាំអំពីលេខរៀងរបស់គណបក្សនយោបាយ ដែលខ្លួន ពេញចិត្ត ។
- អ្នកត្រូវប្រើប៊ិកគូសសញ្ញាគាំទ្រ ក្នុងប្រហោងរាងបួនជ្រុងទ្រវែង បន្ទាប់ពីអ្នកបានស្ទាប និងដឹងច្បាស់អំពីប្រអប់លេខរៀងគណបក្ស ដែលអ្នកពេញចិត្ត។
- អ្នកត្រូវដោះឃ្នាប និងដកសន្លឹកឆ្នោតចេញពីក្របក្រដាសពិសេស រួចបត់តាមផ្នត់ដើម ហើយស្នើសុំប្រធាន គ.ក.ប ឱ្យជួយជូនទៅ ស៊កសន្លឹកឆ្នោតចូលក្នុងហិបឆ្នោត ។

៩.៦.១៩.៤ ប្រធាន គ.ក.ប ត្រូវអនុវត្តភារកិច្ចដូចខាងក្រោម បន្ទាប់ពីអ្នកបោះឆ្នោត ដែលជាជនពិការ បានទទួលក្របក្រដាសពិសេស ដែលមានសន្លឹកឆ្នោត ផ្លូវការនៅខាងក្នុងរួចហើយ ។

- ជួយជូនអ្នកបោះឆ្នោតជាជនពិការនោះទៅកាន់បន្ទប់សម្ងាត់ និង ជួយរកប៊ិកសម្រាប់គូសសញ្ញាគាំទ្រគណបក្សនយោបាយ ។

- ជួយរៀបចំក្រេបក្រដាសពិសេស ឱ្យមានភាពត្រឹមត្រូវ ប្រសិនបើពិនិត្យឃើញថា ក្របក្រដាសពិសេសនោះមានសភាពមិនប្រក្រតី ឬដាក់មិនទំនង ។
- ចេញពីបន្ទប់សម្ងាត់ និងរង់ចាំជួយបន្ថែមទៀត ប្រសិនបើមានសំណូមពរពីអ្នកបោះឆ្នោតនោះ ។

៩.៦.១៩.៥ រាល់ការអនុវត្តនីតិវិធីខាងលើនេះ ត្រូវធ្វើឡើងចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត ។

៩.៦.១៩.៦ គ.ជ.ប ត្រូវរៀបចំឱ្យមានក្របក្រដាសពិសេស មានទម្រង់ជា ០២ (ពីរ)សន្លឹកជាប់គ្នា ដែលមានក្របមុខ និងក្របខាងខ្នង មានទំហំប៉ុនគ្នានឹងសន្លឹកឆ្នោតផ្លូវការនៃឃុំ សង្កាត់នីមួយៗ ហើយក្របក្រដាសពិសេសនេះ ត្រូវចោះប្រហោងរាងបួនជ្រុងទ្រវែងមានទំហំប៉ុនគ្នានៅចំប្រអប់សម្រាប់គូសសញ្ញាគាំទ្រគណបក្សនយោបាយ ដែលមាននៅលើសន្លឹកឆ្នោតផ្លូវការ ។

៩.៦.២០ ក្នុងអំឡុងពេលនៃការបោះឆ្នោតក្នុងថ្ងៃបោះឆ្នោត ប្រសិនបើក្នុងការិយាល័យបោះឆ្នោតគ្មានអ្នកបោះឆ្នោតនោះទេ សមាជិកទី ១ ត្រូវបិទភ្ជិតសន្ទះបិទប្រឡោះ សម្រាប់ស៊កសន្លឹកឆ្នោតជាបណ្តោះអាសន្ន ហើយត្រូវបើកឡើងវិញ នៅពេលមានវត្តមានអ្នកបោះឆ្នោត ។

៩.៦.២១ គ្មានជនណាម្នាក់ ដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត អាចពិនិត្យមើលការគូសសញ្ញាលើសន្លឹកឆ្នោតរបស់អ្នកបោះឆ្នោតឡើយ លើកលែងតែអ្នកដែលជួយអ្នកបោះឆ្នោតជាជនពិការដូចចែងក្នុងចំណុច ៩.៦.១៨ ខាងលើ ។

៩.៦.២១.១ ជនណាក៏ដោយដូចចែងក្នុងចំណុច ៩.៦.២១ ខាងលើ ដែលប៉ុនប៉ងចង់ឃើញការគូសសញ្ញានៅលើសន្លឹកឆ្នោត របស់អ្នកបោះឆ្នោត ជននោះ នឹងត្រូវទទួលការព្រមានពីប្រធាន គ.ក.ប ។ ការប៉ុនប៉ងជាលើកទីពីរ ដើម្បីធ្វើឱ្យបែកខ្ញែកខ្ចាយនូវគោលការណ៍សម្ងាត់នៃការបោះឆ្នោតនឹងត្រូវចាត់ទុកថា ជាការរំលោភទៅលើច្បាប់ ហើយជនដែលមានការពាក់ព័ន្ធ ត្រូវតែបានបណ្តេញចេញពីការិយាល័យបោះឆ្នោត និងត្រូវទទួលទោសតាម ច.ប.ឃ.ស ។

៩.៦.២១.២ លេខាធិការត្រូវកត់ត្រាទុកនូវហេតុការណ៍នេះ ក្នុងកំណត់ហេតុដោយឡែក ដើម្បីធ្វើការតាមដានបន្ថែមទៀត ។

៩.៦.២១.៣ ប្រសិនបើ ជនប្រព្រឹត្តអំពើល្មើសលើគោលការណ៍សម្ងាត់នៃការបោះឆ្នោត ដូចចែងក្នុងចំណុច ៩.៦.២១.១ ខាងលើ ជាបេក្ខជនឈរឈ្មោះ បោះឆ្នោត ប្រធាន គ.ក.ប ត្រូវបញ្ជូនកំណត់ហេតុស្តីពីហេតុការណ៍នោះ ទៅ គឃ.សប ។

៩.៦.២១.៤ ពេលបានទទួលកំណត់ហេតុដូចចែងក្នុងចំណុច ៩.៦.២១.៣ ខាងលើភ្លាម គឃ.សប ត្រូវធ្វើការស៊ើបអង្កេតអំពើរំលោភនោះជាបន្ទាន់ ហើយប្រសិនបើមានភស្តុតាងបញ្ជាក់ថាពិតប្រាកដមែន ត្រូវតែប្តឹងជនប្រព្រឹត្តអំពើល្មើសទៅ គជ.ខប ដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

៩.៦.២២ អ្នកបោះឆ្នោតណាម្នាក់ ដែលបានធ្វើឱ្យខូចសន្លឹកឆ្នោតដោយអចេតនា ដោយធ្វើឱ្យរហែក ឬធ្វើឱ្យប្រឡាក់ ឬដែលបានគូសសញ្ញានៅលើសន្លឹកឆ្នោតរួចហើយ តែបានប្តូរចិត្តវិញ គាត់អាចសុំសន្លឹកឆ្នោត ០១ (មួយ) សន្លឹកផ្សេងទៀតពីប្រធាន គ.ក.ប ។

៩.៦.២២.១ អ្នកបោះឆ្នោតដែលស្នើសុំសន្លឹកឆ្នោត ០១ (មួយ) សន្លឹកផ្សេងទៀត ត្រូវបត់សន្លឹកឆ្នោតខូចតាមផ្នត់ដើម ដើម្បីឱ្យសញ្ញាដែលបានគូសស្ថិតនៅខាងក្នុងផ្នត់ រួចប្រគល់ជូនប្រធាន គ.ក.ប ។

៩.៦.២២.២ ប្រធានត្រូវស៊កសន្លឹកឆ្នោត ដែលខូចនោះទៅក្នុងស្រោមសំបុត្រមួយដែលមានកាខ្ទងស្រាប់ថា " សន្លឹកឆ្នោតខូច "។

៩.៦.២២.៣ លេខាធិការដែលបានគូសសញ្ញាសម្គាល់ម្តងហើយ ក្នុងប្រអប់នៅប៉ែកខាងដើមទន្ទឹមនឹងឈ្មោះគាត់ក្នុងបញ្ជីបោះឆ្នោត ដូចចែងក្នុងចំណុច ៩.៦.១១.៣ ខាងលើ មិនចាំបាច់គូសសញ្ញាសម្គាល់ជាលើកទីពីរឡើយ ប៉ុន្តែត្រូវកត់ចំណុចទុក សម្រាប់សរសេរចូលក្នុងកំណត់ហេតុនៃការបោះឆ្នោត ។

៩.៦.២២.៤ ប្រធាន ត្រូវអនុញ្ញាតឱ្យអនុប្រធានផ្តល់សន្លឹកឆ្នោត ០១ (មួយ) សន្លឹកផ្សេងទៀតចំពោះអ្នកបោះឆ្នោតដែលចែងក្នុងចំណុច ៩.៦.២២ តែមួយលើកគត់ និងត្រូវធានាឱ្យមានសន្លឹកឆ្នោតគ្រប់គ្រាន់សម្រាប់ការបោះឆ្នោតនៅថ្ងៃបោះឆ្នោត និងត្រូវរំលឹកអនុប្រធានឱ្យណែនាំអ្នកបោះឆ្នោតបន្ទាប់តាមខ្លឹមសារនៃចំណុច ៩.៦.១៤.២ ខាងលើ ដោយផ្អែកលើចំនួនជាក់ស្តែងនៃសន្លឹកឆ្នោតនៅការិយាល័យនោះ ។

៩.៦.២២.៥ ក្នុងករណី មានអ្នកបោះឆ្នោតមួយចំនួនជាបន្តបន្ទាប់គ្នាសុំសន្លឹកឆ្នោត ០១ (មួយ) សន្លឹកឆ្នោតផ្សេងទៀត ដូចចែងក្នុងចំណុច ៩.៦.២១ ខាងលើ ដែលអាចចាត់ទុកថាជាភាពមិនប្រក្រតីមួយនោះ ប្រធាន គ.ក.ប អាច សម្រេចមិនព្រមផ្តល់សន្លឹកឆ្នោត ០១ (មួយ) សន្លឹកផ្សេងទៀត តាម ការស្នើសុំទេ ហើយឱ្យលេខាធិការកត់ត្រាបញ្ហាទាំងនេះ ចូលក្នុង កំណត់ហេតុនៃការបោះឆ្នោត ។

៩.៦.២៣ ប្រសិនបើ ភ្នាក់ងារនៃគណបក្សនយោបាយណាម្នាក់ជំទាស់ ឬតវ៉ានឹងកិច្ចប្រតិបត្តិការ បោះឆ្នោត ឬសេចក្តីសម្រេចណាមួយរបស់ គ.ក.ប គាត់ត្រូវលើកការជំទាស់ ឬតវ៉ានោះ ដោយផ្ទាល់ទៅប្រធាន គ.ក.ប ដោយបង្ហាញអំពីមូលហេតុ ឬ/និងភស្តុតាងដែលនាំ ឱ្យគាត់ជឿថា មានភាពមិនប្រក្រតី ឬការរំលោភច្បាប់ ឬ/និងការរំលោភ ប.ន.ឃ.ស ក្នុងការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ។

៩.៦.២៣.១ ប្រសិនបើ យល់ឃើញថាសមហេតុផល ប្រធានត្រូវបញ្ឈប់ជាបណ្តោះ អាសន្ននូវកិច្ចប្រតិបត្តិការបោះឆ្នោត ដើម្បីស្តាប់ការជំទាស់ ឬតវ៉ា របស់ភ្នាក់ងារគណបក្សនយោបាយនោះ ហើយបន្ទាប់មកពិភាក្សា បញ្ហានេះ ជាមួយនឹងសមាជិក គ.ក.ប ដទៃទៀត ។

៩.៦.២៣.២ បន្ទាប់ពីបានពិនិត្យឡើងវិញអំពីករណីដែលបានលើកជំទាស់ ឬតវ៉ា ប្រសិនបើ ប្រធាន គ.ក.ប យល់ព្រមតាមការជំទាស់ ឬតវ៉ា ប្រធាន ត្រូវណែនាំ និងរំលឹក សមាជិក គ.ក.ប និងអ្នកដែលមានវត្តមានក្នុង ការិយាល័យបោះឆ្នោត អំពីខ្លឹមសារពាក់ព័ន្ធ ដែលចែងក្នុង ច.ប.ឃ.ស និង ប.ន.ឃ.ស ហើយត្រូវចាត់វិធានការដោះស្រាយភាពមិនប្រក្រតីនោះ ជាបន្ទាន់ ។

៩.៦.២៣.៣ ប្រសិនបើប្រធាន គ.ក.ប បដិសេធការជំទាស់ ឬតវ៉ា គាត់ត្រូវផ្តល់ហេតុផល ពាក់ព័ន្ធនឹងការបដិសេធនោះជូនភ្នាក់ងារគណបក្សនយោបាយ ។

៩.៦.២៣.៤ ប្រសិនបើភ្នាក់ងារគណបក្សនយោបាយនៅតែជំទាស់ ឬតវ៉ា ប្រធាន គ.ក.ប ត្រូវកត់ត្រាការជំទាស់ ឬតវ៉ានេះ ក្នុងកំណត់ហេតុនៃការ បោះឆ្នោត (ទ.១១០១) ដោយឱ្យអ្នកជំទាស់ ឬតវ៉ានោះ ចុះហត្ថលេខា លើកំណត់ហេតុនេះ ។

៩.៦.២៣.៥ ប្រសិនបើភ្នាក់ងារគណបក្សនយោបាយនោះមិនយល់ព្រមចុះហត្ថលេខាករណីនៃការជំទាស់ ឬតវ៉ានោះ មិនត្រូវបានកត់ត្រាក្នុងកំណត់ហេតុនៃការបោះឆ្នោតទេ ។

៩.៦.២៣.៦ ការសម្រេចរបស់ប្រធាន គ.ក.ប ជាការសម្រេចបានការ ក្នុងកម្រិតសមត្ថកិច្ចរបស់ខ្លួន ហើយប្រធានត្រូវប្រកាសបន្តដំណើរការបោះឆ្នោតតទៅទៀត។

៩.៦.២៣.៧ ចំណុច ៩.៦.២៣.៦ ខាងលើ មិនបានច្រានចោលជាមុននូវការ ដែលភ្នាក់ងារគណបក្សនយោបាយណាម្នាក់ ចង់បន្តប្ដឹងជំទាស់ ឬតវ៉ា ទៅ គឃ.សប អំពីករណីដែលគាត់បានលើកជំទាស់ក្នុងការិយាល័យបោះឆ្នោតនោះទេ ប៉ុន្តែក្នុងស្ថានភាពនេះ គាត់ត្រូវតែយល់ព្រមទទួលយកនូវវិធានការនៃការគ្រប់គ្រងរបស់ប្រធាន គ.ក.ប និងមិនត្រូវរំខាន ឬជ្រៀតជ្រែកធ្វើឱ្យរាំងស្ទះដល់កិច្ចប្រតិបត្តិការបោះឆ្នោតឡើយ ។

៩.៦.២៣.៨ ប្រធានត្រូវផ្ដល់ ទ.១២០២ សម្រាប់បំពេញពាក្យបណ្ដឹង ប្រសិនបើភ្នាក់ងារគណបក្សនយោបាយស្នើសុំសម្រាប់ប្ដឹងបន្តទៅ គឃ.សប ។

៩.៦.២៤ ប្រសិនបើមាន អ្នកបោះឆ្នោតណាម្នាក់រំខានដល់កិច្ចប្រតិបត្តិការបោះឆ្នោត ទោះបីគាត់ស្ថិតនៅក្នុងការិយាល័យបោះឆ្នោត ឬកំពុងឈរតម្រង់ជួរនៅខាងក្រៅការិយាល័យក្ដី ប្រធាន គ.ក.ប ត្រូវណែនាំឱ្យគាត់រក្សារបៀបរៀបរយ ។ ក្នុងករណីអ្នកបោះឆ្នោតនោះបដិសេធមិនព្រមគោរពតាមបញ្ជារបស់ខ្លួន ប្រធាន គ.ក.ប ត្រូវស្នើកម្លាំងសន្តិសុខឱ្យបណ្ដេញបុគ្គលនោះចេញ ឬឃាត់ខ្លួនបុគ្គលនោះ រហូតដល់ការបោះឆ្នោតត្រូវបានបញ្ចប់។

៩.៦.២៥ ប្រធាន គ.ក.ប អាចស្នើសុំកម្លាំងសន្តិសុខឱ្យរៀបចំសាឡើងវិញ នូវរបៀបរៀបរយនៅខាងក្នុង និងខាងក្រៅការិយាល័យបោះឆ្នោត ប្រសិនបើ កិច្ចប្រតិបត្តិការបោះឆ្នោតត្រូវបានរំខានដល់កម្រិត ដែលអ្នកបោះឆ្នោតមិនអាចធ្វើការបោះឆ្នោត បន្តទៀតបាន ឬធ្វើឱ្យការបោះឆ្នោតមិនអាចប្រព្រឹត្តទៅដោយសេរី ។ ការរំខានដល់អ្នកបោះឆ្នោត ឬដល់ការប្រព្រឹត្តទៅនៃការបោះឆ្នោត គឺជាសកម្មភាពទាំងឡាយណានៅខាងក្នុង ឬបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត ដូចខាងក្រោមនេះ ៖

៩.៦.២៥.១ ការបញ្ចេញសម្រែកខ្លាំងៗ ឬការបញ្ចេញសម្ដីគំរាមកំហែង ឬជេរប្រមាថ មាក់ងាយ ។

៩.៦.២៥.២ ការធ្វើសកម្មភាពរារាំងអ្នកបោះឆ្នោត មិនឱ្យទៅបោះឆ្នោត ។

៩.៦.២៥.៣ ការរុញច្រានដោយប្រើកម្លាំងធ្ងន់ ។

៩.៦.២៥.៤ ការគប់វត្ថុផ្សេងៗសំដៅអ្នកបោះឆ្នោត ឬការិយាល័យបោះឆ្នោត។

៩.៦.២៥.៥ ការអុកឡុកនៃបុគ្គលណាម្នាក់ ឬច្រើននាក់ ដែលធ្វើឱ្យរំខានដល់អ្នកបោះឆ្នោត ។

៩.៦.២៥.៦ ការបញ្ចេញអាកប្បកិរិយា និងភាសាមិនសមរម្យ ។

៩.៦.២៥.៧ ការបញ្ចេញឱ្យឃើញនូវអាវុធ គ្រឿងផ្ទុះ ឬសារធាតុផ្សេងៗ ប្រកបដោយគ្រោះថ្នាក់ ។

៩.៦.២៦ ប្រសិនបើ ការបោះឆ្នោតឈានដល់ម៉ោង ១៥:០០ (ដប់ប្រាំ) រសៀល នៃថ្ងៃបោះឆ្នោត ដែលជាពេលវេលាកំណត់ សម្រាប់ការបញ្ចប់ដំណើរការបោះឆ្នោត ហើយនៅតែមានអ្នកបោះឆ្នោតស្ថិតក្នុងការិយាល័យបោះឆ្នោត ឬឈរតម្រង់ជួរ ឬស្ថិតនៅក្នុងបរិវេណខាងក្នុងការិយាល័យបោះឆ្នោតទៀត អ្នកបោះឆ្នោតទាំងនោះត្រូវតែបានអនុញ្ញាតឱ្យបោះឆ្នោត ។

៩.៦.២៦.១ ក្នុងករណីនេះ សមាជិកទី ២ ត្រូវប្រកាសអញ្ជើញអ្នកបោះឆ្នោតដែលមានវត្តមាននៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត និងត្រូវប្រមូលយក អ.ខ ឬ ឯ.អ ពីអ្នកបោះឆ្នោត ដែលនៅក្នុងជួរ ដោយចាប់ផ្តើមពីអ្នកបោះឆ្នោត ដែលឈរក្រោយគេបង្អស់ រហូតដល់អ្នកនៅខាងមុខគេបង្អស់រួចប្រគល់ទៅឱ្យសមាជិកទី ៣ នៅត្រង់មាត់ទ្វារ ។

៩.៦.២៦.២ សមាជិកទី ៣ ត្រូវហៅឈ្មោះអ្នកបោះឆ្នោតម្នាក់ម្តងៗ រហូតដល់អ្នកបោះឆ្នោតចុងក្រោយបង្អស់ឱ្យចូលក្នុងការិយាល័យបោះឆ្នោត ដើម្បីបោះឆ្នោត តាមលំដាប់លំដោយរហូតដល់អស់អ្នកបោះឆ្នោត ។

៩.៦.២៦.៣ អ្នកបោះឆ្នោត ដែលគ្មានវត្តមាននៅខាងក្នុងការិយាល័យបោះឆ្នោត ឬនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត នៅនាទីចុងក្រោយនាម៉ោង ១៥:០០ (ដប់ប្រាំ) រសៀល នៃថ្ងៃបោះឆ្នោតទេនោះ អ្នកបោះឆ្នោតទាំងនោះ ពុំត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតឡើយ ។

៩.៦.២៧ ប្រសិនបើ អ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត មិនទាន់បានមកបោះឆ្នោតគ្រប់គ្នាទេ ទោះបីគ្មានអ្នកបោះឆ្នោតឈររង់ចាំបោះឆ្នោតក្តី ប្រធាន គ.ក.ប មិនអាចបិទការបោះឆ្នោត នៅការិយាល័យរបស់ខ្លួន នៅមុនម៉ោង ១៥:០០ (ដប់ប្រាំ) រសៀល នៃថ្ងៃបោះឆ្នោតបានឡើយ ។

៩.៦.២៨ ប្រសិនបើ អ្នកបោះឆ្នោតទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត បានបោះឆ្នោតគ្រប់គ្នាហើយ ប្រធាន គ.ក.ប អាចប្រកាសបញ្ចប់ការបោះឆ្នោតនៅការិយាល័យរបស់ខ្លួន នៅមុនម៉ោង ១៥:០០ (ដប់ប្រាំ) រសៀល ។

៩.៦.២៩ ក្នុងករណី កាលៈទេសៈមានអាសន្ន ដែលនាំឱ្យមានគ្រោះថ្នាក់ ឬគំរាមកំហែង ដល់សុវត្ថិភាពមន្ត្រីបោះឆ្នោត និងអ្នកបោះឆ្នោត នៅក្នុងបរិវេណនៃការិយាល័យបោះឆ្នោតនាថ្ងៃបោះឆ្នោត ប្រធាន គ.ក.ប អាចសម្រេចមិនបើក ឬអាចបិទការិយាល័យបោះឆ្នោតរបស់ខ្លួន ដោយផ្អែកតាមការកំណត់របស់ គ.ជ.ប ដូចចែងក្រោមប្រការ ១២.១ ជំពូកទី ១២ នៃ ប.ន.ឃ.ស នេះ ។